# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ហ្លួងនិពន្ធមន្ត្រី ញ៉ុក - ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះទេពសត្ថា ស្នួរ - ហាយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

| *ផ្នែកអក្សរសាស្ត្រ* | បញ្ជីរឿង | ទំព័រ |
|---|---|---|
| អ្នកឧកញ៉ា ឈិម - ក្រសេម | ព្រះរាជពង្សាវតារ ភាគទី ១ សម័យលង្វែក (ហ្វណាន) ........................ | ៨១ |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក - ថែម | ប្រវត្តិសាស្ត្រសង្ខេប ប្រទេសឥណ្ឌា ....... | ១០០ |
| លោក វ៉ាយ - ប៊ុក តាយបញ្ញ | ស្តុកសិតកេក (តមក - ចប់) ......... | ១១៦ |
| លោកអាចារ្យ ទិញ - ប្រាជ្ញ | រឿងធ្វើស្រែខ្មែរ នៅកម្ពុជាក្រោម (កូស័ងស៊ីន) (តមក) .............................. | ១២៤ |
| អ្នកឧកញ៉ាព្រះឃ្លាំង ឧង | រឿងភោគកុលកុមារ (តមក) ............ | ១៣២ |
| *ផ្នែកសាសនា* | | |
| ឃុន បណ្ណានុរ័ក្ស ប៊ូ - ប៊ូ | វិជ្ជារក្សាចិត្ត ក្នុងបច្ចុប្បន្ន ................. | ១៣[illegible] |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក - ថែម | ពន្ធិអាស៊ីទិប (តមក) ..................... | ១៤៤ |
| ព្រះមហា កែវ - ណាព្រី | មង្គលកុណ្ឌលិនិទាន (ពីលេខ ១២ ឆ្នាំ ១៩៤៨) | ១៥០ |
| *កំណត់ហេតុប្រវត្តិការណ៍* | | |
| ក្រសួងធម្មការ | ការតាំងចៅអធិការថ្មី (តមក) ............ | ១៥៣ |

ឆ្នាំទី ២១ — លេខ ២ ខែកុម្ភៈ ឆ្នាំ ១៩៤៩ — ដំឡៃជាវ ១ ឆ្នាំ ៩៦ រៀល ។

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : Luong Nibandhamantrî
NHOK-THÈM, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable
Brah Déb Satthā So-HAY membre de la Commission du Tripitaka

## TABLE DES MATIÈRES

**Partie littéraire :**


| | | page |
|---|---|---|
| Neak Oknha CHHIM-KRASEM Député | Histoire ancienne du Camdodge .... | 81 |
| Luong Nibandhamantrî Nhok-Thèm | Histoire sommaire de l'Inde ....... | 100 |
| M. Ray-Buc chef comptable (I. B.) | Recueil de maximes des écrivains grecs (suite et fin).................... | 116 |
| Monsieur Dinh-Prach | Travaux des champs chez les Cambodgiens de Cochinchine (suite)....... | 124 |
| Feu Neak Oknha Brah khleang-Nong | Bhog Kul Kumâr (en vers) (suite)... | 132 |


**Partie religieuse:**


| | | |
|---|---|---|
| Khun Pannānuraks Bou-Po (I.B.) | Entrainement spirituel (texte tiré du Sumanglavilâsinî)................. | 137 |
| Luong Nibandhamantri NHOK-TREM | Lumière de l'Asie (suite)......... | 144 |
| Brah Mahâ KEO-NAKRI | Mattbakundalinidân (suite du nº 12 de 1948) ........................ | 150 |


**Notes et chroniques**


| | | |
|---|---|---|
| Ministère des Cultes | Nomination de nouveaux Chau Adhikâr (suite).................. | 157 |


21e Année: Nº 2 Février 1949 — Prix d'abonnement 96$00 par an.

# ព្រះរាជពង្សាវតារភាគទី ១

## សម័យនគរភ្នំ (ហ្វូណាន)

## ក្រសេម ទេពពិទូរ

### មូលប្រវត្តិសាស្ត្រប្រទេស-ប្រជាជាតិខ្មែរ អំពីដើម

តាមដែលបានស្រាវជ្រាវតាមផ្លូវប្រវត្តិសាស្ត្រមកហើយ ប្រាកដថា នៅក្នុងផែនលោកភាគខាងត្បូង ដែលផុតអំពីមជ្ឈិមប្រទេស ជាទីតាំងប្រទេសឥណ្ឌូចិន នៅត្រង់កណ្តាលនៃប្រទេសទាំងនោះ គឺត្រង់ដែលហៅថា ទក្ខិណាបថ ឬ ទក្សិណាទិគោល មានប្រទេស ១ ឈ្មោះ «កុមេរុ[1]» ជាប្រទេសធំ មានប្រជាជនកុះករច្រើន, ខ្មែរយើងដើមឡើយ (មុនដែលផ្លាស់មកនៅក្នុងកម្ពុជរដ្ឋ) អាស្រ័យនៅក្នុងកុមេរុរដ្ឋនោះៗ ជាប្រទេសរបស់ខ្មែរអំពីបុរាណកាលមក ។

ដោយហេតុប្រជាជាតិឈ្មោះ «កុមេរុ» ប្រទេសដែលប្រជាជាតិនោះអាស្រ័យនៅ ក៏គេនាំមានឈ្មោះថា «កុមេរុ» ឬដោយហេតុថា ប្រទេសឈ្មោះថា «កុមេរុ» ប្រជាជាតិដែលនៅក្នុងប្រទេសនោះ ក៏គេនាំមានឈ្មោះថា «កុមេរុ» ដែរ ។ ឈ្មោះជាតិខ្មែរហៅត្រឹមត្រូវតាមរូប

---

១ ក្នុងសៀវភៅ (ភាសាខ្មែរ) របស់លោកអៀវ-កើស ថាស័ព្ទនេះជាឈ្មោះហិ[illegible]ក ។ តាមសេចក្តីនិយមរបស់ពួកហិណ្ឌូជាឈ្មោះដែលមានស្រះ ។ ទៅខាងដើមខាងចុង ដូចយ៉ាង សុមេរុ កុមេរុ ជាដើមជាឈ្មោះ ទន្ទល ។

ស័ព្ទដើមថា កុមេរុ ដូច្នេះ តែតាមសំនៀងនិយាយជាធម្មតាថា កុមេរុ៍ ទំនងដូចឈ្មោះភ្នំសុមេរុ គេហៅទៅក្រុមសុមេរុ៍ ។ ព្រោះយូរមកឈ្មោះនេះបានក្លាយចេញទៅទៀត ប្រាកដនៅសិលាចារិករបស់ខ្មែរថា «ក្មេរ» ទៅជាសំនៀងផង, ក្រោយសម័យសិលាចារិកមកបានប្រែទៅជា «ខ្មែរ» កាលត្រូវការប្រែជាភាសាមគធៈគេសរសេរថា ខេមរៈ តាំងនេះដោយហេតុគេភ្លេចរូបស័ព្ទដើមបង់មកយូរហើយ ។

លុះមកដល់ក្រោយពុទ្ធកាលជាច្រើនឆ្នាំ ខ្មែរយើងចេញផ្សាយមកតាំងឥស្សរភាពនៅក្នុងដែនសុវណ្ណភូមិនេះ ។

## សុវណ្ណភូមិនិងប្រជាជាតិ

ដែនដីដ៏តាំងនៅក្នុងរវាងប្រទេសឥណ្ឌា និងប្រទេសចិន ហៅថា «សុវណ្ណភូមិ» (ស្រុកមាស) ត្រូវនឹងពាក្យក្នុងបច្ចុប្បន្ននេះថា ឥណ្ឌូចិន តែក្នុងសិលាចារិកកល្យាណីរបស់មន ឃើញគេប្រើប្រទេសមន ជាសុវណ្ណភូមិ ។ មុនដែលខ្មែរបានមកតាំងឥស្សរភាពមិនយូរប៉ុន្មាន. ដែនសុវណ្ណភូមិមានមនុស្សជាតិតាំងឥស្សរភាពមកហើយ ៥ គណបក្សគឺ:

១- អាណាចក្ររាមញ្ញ ជារបស់ជាតិមន នៅខាងលិចប្រទេសសៀមសព្វថ្ងៃនេះ តាំងរាជធានីនៅសុធម្មនគរ (សាថុំ) ក្រុងនេះធ្លាក់ទៅជារបស់ភូមា ។

២ - អាណាចក្រមាល័យ ជារបស់ជាតិជ្វាម៉ាលេយូ តាំងពីដើមទី-ដំបូងនៅសិង្ហបុរី ( សិង្គបូរ ) ។

៣ អាណាចក្រលក់ ជារបស់ជាតិលក់ ឬលាវដើម នៅក្នុងដែនសៀមសព្វថ្ងៃនេះ តែអាណាចក្រនេះត្រូវបំបែកចេញជា ៣ រដ្ឋ ហៅឈ្មោះតាមដែលខ្មែរហៅក្នុងជាន់ក្រោយថា

ក - រដ្ឋទ្វារវតី តាំងពីដើមទីនៅស្រុកដែលហៅក្នុងកាលឥឡូវនេះថា នគរបឋម ។

ខ - រដ្ឋយោនក ឬ យាង នៅក្នុងមណ្ឌលភាយព្យរបស់សៀមសព្វថ្ងៃនេះតាំងពីដើមទីនៅស្រុកជិនយ៉ាង ភងល្អិចស្រុកជៀងសែន ។

គ រដ្ឋគោត្របុរ នៅក្នុងមណ្ឌលភាគឦសានរបស់សៀមក្នុងបច្ចុប្បន្នតាំងពីដើមទីនៅនគរភ្នំសព្វថ្ងៃនេះ ។

ជាតិលក់ញែកគ្នាជា ៣ ពួកត្រង់ត្រង់រដ្ឋទាំង ៣ នេះ ដទៃពីគ្នា តែនៅក្នុងឋានៈជាភាតរភាពផងគ្នា ។

៤ អាណាចក្រភ្នំ (កម្ពុជរដ្ឋ) ជារបស់ជាតិ ១ សឹងជាអំបូរជ្វា[1] តាំងពីដើមទីដំបូងនៅវាំងភ្នំ និងបាណាម ។

---

១ ជាតិជ្វាញែកគ្នាទៅតាមកោះតាមឈ្មោះសមុទ្រប៉ាស៊ីហ្វិក តាំងពីកោះជ្វាកោះសុមាត្រា កោះបង់ក្អ កោះពិណាំង សិង្គបូរ និងក្រង់ប្រទេសកម្ពុជាសព្វថ្ងៃនេះតែញែកជាអាណាចក្រផ្សេងៗគ្នា ។

៥ - អាណាចក្រចម្ប៉ា ជារបស់ជាតិចាម្ប៉ា នៅខាងកើតកម្ពុជាផង គឺប្រទេសវៀតណាមសព្វថ្ងៃនេះ តាំងពីកាលជាមិនចូលនៅក្នុង ។

ក្រៅអំពីជាតិទាំងនេះ ក៏មានមនុស្សសន្តិមជាសន្តិមតូចៗ រុំរុមនៅក្នុងចំពួកមនុស្សព្រៃ គឺ ពណ៌ សម្រែ លាវ កួយ ចារ៉ាយ គ្មានព្រះរាជារដ្ឋាភិបាលគ្រប់គ្រង ដូចប្រទេសទាំងឡាយដែលពោលមកខាងលើទេ ។

## ខ្មែរផ្សាយមកសុវណ្ណភូមិ

ក្រោយពុទ្ធកាល ប្រមាណពីពេលពុទ្ធសតវត្សទី ២ ដល់ទី ៦ ប្រជាជាតិខ្មែរបានមកតាំងលំនៅដូរនឹងមកកា ហើយនៅក្នុងដែនសុវណ្ណភូមិ ជាហូរហែមក ទំនងដូចជាតិចិនដែលផ្សាយក្នុងកម្ពុជាក្នុងបច្ចុប្បន្ន ។

ដែលថា «ខ្មែរកើតផ្សាយមកពីសុវណ្ណ» ដូច្នេះ តើមានអ្វីខ្លះជាសម្គាល់ ? ។ គឺថា ក្រៅពីជាតិឈ្មោះប្រទេសដូចបានពោល ហើយ នៅមានភស្តុតាងយ៉ាងដទៃទៀតជាច្រើនយ៉ាងជាសម្គាល់ គឺ ៖

ក - លក្ខណៈអក្សរ និង ភាសា

ខ - លទ្ធិប្រពៃណី និង សាសនា

គ - ពង្សាវតារ និង សេចក្តីតហេតុ ។

**លក្ខណៈអក្សរនិងភាសា** — យើងត្រូវដឹងជាមុនថា អក្សរ សៈណ្ណា) និងអក្សរខ្មែរយើង មានដើមកំណើតមកពីអក្សរព្រាហ្មណ៍ដូច សៈណ្ណា) ជាមួយគ្នា ក្នុងជាន់ដើមមានលក្ខណៈដូចគ្នា តែឥឡូវសរសេរ

យូរទៅ ហើយបានថែមទាំងបែកទៅនៅប្រទេសឆ្ងាយពីគ្នា លក្ខណៈអក្សរក៏សម្រេច ៗ ស្ទើរគ្នាចេញទៅជាផ្លាស់ដាច់ ទោះបីយ៉ាងណាក៏នៅមានស្នាមល្អមឲ្យយើងដឹងបានថាជាអំបូរជាមួយគ្នា ។ ការនឹងបញ្ជាក់ពីលក្ខណៈអក្សរ យើងត្រូវពិនិត្យតាមសិលាចារឹក សឹងជាគំរូដែលគេបានចារិកទុកតាំងពីសម័យនោះ ។ ទាំងក្នុងប្រទេសឥណ្ឌា ទាំងក្នុងប្រទេសកម្ពុជា ។ សិលាចារឹកក្នុងប្រទេសទាំងពីរនេះ ត្រូវចាត់តាមសម័យមុន-ក្រោយជា ២ ថែប គឺថែបជាន់ដើម និងថែបជាន់ក្រោយ ។

ថែបជាន់ដើមក្នុងឥណ្ឌា កំណត់ត្រឹមសិលាចារឹករបស់ក្សត្រិយ៍វង្សគុប្តៈ និងវង្ស បល្លវៈ ដែលមានចារិកទុកនៅបេតិយ នៅទេវស្ថានផ្សេង ៗ ក្នុងដែន សមុទ្រគុប្តៈ កញ្ចិបុរ និងមទ្រាស ។ សិលាចារឹកថែបជាន់ក្រោយគេឃើញមានរៀងរាយជាច្រើនអន្លើ តាំងពីភាគពាក់កណ្តាលដែននោះចុះមកដល់ចុងដែនខាងត្បូងនិងខាងកើត ។

សិលាចារឹកខ្មែរថែបជាន់ដើម កំណត់រួមពីសម័យនគរភ្នំដល់ខាងដើមសម័យនគរធំ ត្រឹមរជ្ជកាលព្រះបាទឥន្ទ្រវរ្ម័នទី ១ (ព. ស. ១៤២០-១៤៣២) នៅហរិហរាល័យ ។ ថែបជាន់ក្រោយ កំណត់ពីត្រឹមរជ្ជកាលព្រះបាទយសោវរ្ម័នទី ១ (ព. ស. ១៤៣២-១៤៥៤) ដល់ចុងសម័យនគរធំ ។

អក្សរបែបជាន់ដើមទាំងខាងឥណ្ឌា ទាំងខាងខ្មែរ មានលក្ខណៈ ទ្រង់មូលៗ បែបទន់ល្មន់ ត្រូវនឹងបែបដែលយើងហៅថា៖ អក្សរមូល ។ អក្សរបែបជាន់ក្រោយមានលក្ខណៈទ្រង់ចុងជ្រុង មានទ្រនុងស្រួចៗ ត្រូវនឹងបែបដែលយើងហៅថាអក្សរខម ។

អក្សរបុរាណទាំង ២ បែបនេះ អាចជាគោលដ៏សំខាន់សម្រាប់ប្រៀបធៀបប្រវត្តិសាស្ត្របានយ៉ាងល្អ ។ អ្នកប្រាជ្ញបុរាណគតិមានលោក ចជិតកិបាកំងជាដើម បានពិនិត្យឃើញសេចក្តីយល់ចុះថា អក្សរឥណ្ឌានឹងអក្សរខ្មែរមានលក្ខណៈប្រហែលគ្នាទៅតាមសម័យ គឺបែបជាន់ដើមឥណ្ឌាប្រហែលគ្នានឹងបែបជាន់ដើមខ្មែរ, បែបជាន់ក្រោយឥណ្ឌាប្រហែលគ្នានឹងបែបជាន់ក្រោយខ្មែរ; ទោះបើមានល្អៀងគ្នាខ្លះ ក៏ព្រោះតែហេតុនៃតួអក្សរនោះៗ ដែលគេបន្ថែមឡើង តាមសេចក្តីនិយម ។

ឯភាសានោះ ប្រាកដនៅសិលាចារឹកខ្មែរ មាន ២ ភាសា គឺភាសាសំស្ក្រឹតនិងភាសាខ្មែរ ។ ទាំងនេះ យើងអាចដឹងបានថា ភាសាសំស្ក្រឹតមានដើមកំណើតនៅឥណ្ឌា ខ្មែរយើងខ្ចីបេះ ខ្ចីប្រើមកហើយ, កាលពុះមក នៅគង់ផងដែកាយនេះ ក៏នាំយកភាសាសំស្ក្រឹតមកប្រើក្នុងផ្ទរការផង ភាសាសំស្ក្រឹតទើបឃើញប្រាកដនៅសិលាចារឹកខ្មែរសឹងមានសេចក្តីជាផ្ទរការ ។ ឯភាសាខ្មែរនោះសោត គេឃើញលាយចម្រុះទៅដោយភាសាសំស្ក្រឹត, ទាំងនេះជាសម្គាល់ ១ យ៉ាង ។

លទ្ធិប្រពៃណីនិងសាសនា – លទ្ធិប្រពៃណីផ្សេងៗ មានពិធីចូឡាកេបនៈ (ពិធីកោរកំបោយក្មេង), ពិធីសាក់ហាវហាមផ្ដល, ពិធីទាទសមាស, និងរបៀបទាជសាស្ត្រ (កំ) ជាដើម ដែលខ្មែរយើងនិយមធ្វើនៅក្នុងប្រទេសនេះ (ខ្ញុំទេពពិទូរ ក្រសេម) បានពិនិត្យនិងប្រៀបធៀបគ្នាហើយ ឃើញដូចគ្នាទាំងឈ្មោះ ទាំងរបៀបដែលគេនិយមធ្វើនៅឥណ្ឌា ទោះមានល្អៀងគ្នាខ្លះ ក៏ចំពោះភាគ ១ ជាឯកទេសប៉ុណ្ណោះ នៅមានគោលដល់លួមឲ្យយើងសន្និដ្ឋានដើមជាខបានថា ពិធីទាំងនេះផ្សាយមកពីឥណ្ឌា ដោយខ្មែរយើងជាអ្នកនាំមកដោយខ្លួនឯង ។

ឯសាសនានោះ គឺសាសនាព្រាហ្មណ៍ និងព្រះសាសនាពុទ្ធ, សាសនាទាំងពីរនេះមានដើមកំណើតនៅក្នុងឥណ្ឌា កាលខ្មែរយើងផ្សាយមកនៅក្នុងដែនដីនេះ ក៏នាំយកមកប្រតិស្ឋានក្នុងប្រទេសរបស់ខ្លួន សម្រាប់ប្រព្រឹត្តប្រតិបត្តិ តាំងពីដំបូងមក សឹងមានបុរាណស្ថាន ដូចយ៉ាងប្រាសាទ-ប្រាង្គទេវស្ថាន ពុទ្ធវិហារ និងបុណណាគ្រ ដូចយ៉ាងទេវរូបព្រះពុទ្ធរូបជាដើម ដែលខ្មែរយើងសាងឡើងដោយថ្ម-ឥដ្ឋ និងដោយសម្រិទ្ធិ សឹងមានពាយពាសនៅក្នុងព្រះរាជអាណាចក្រដល់សព្វថ្ងៃនេះ ។ ទាំងនេះសមដោយសេចក្ដីដែលប្រាជ្ញនៅក្នុងពង្សាវតារចិនឈ្មោះណានគ្យូជូ និងលាំងជូ ថា «កាវ្យធម៌កល្បផ្សាយមកក្នុងឥណ្ឌាចិន មានច្រើនផ្សេងៗ

ចូលមកគ្របលើវិជ្ជាស្រុកកាយជាច្រើនយ៉ាង គឺវិជ្ជាអក្សរសាស្ត្រ, ភាសាសំស្ក្រឹត, សាសនា, វិរ័ប្រញ, ទស្សនា ។ល។ ។ ទាំងនេះ យើងអាចកត់បានយ៉ាងពេញថា អ្នកដែលនាំអារ្យធម៌ពីឥណ្ឌាមកផ្សាយក្នុងដែនដីកាយនេះ គឺខ្មែរគោរស្រ័យជាតិខ្មែរជាអ្នកមានអារ្យធម៌ខ្ពង់ខ្ពស់ ទាំងមានឥទ្ធិពល ទើបអាចផ្សាយអារ្យធម៌របស់ខ្លួនទៅលើជាតិទាំងឡាយដែលនៅក្រោមអំណាច ទីងជាតិទាំងឡាយដែលនៅជិតខាងទៀតផង, ដោយហេតុនេះ ទើបមានគាថាថា «ខ្មែរជាឥណ្ឌាទី ២ នៅក្នុងដែនសុវណ្ណភូមិ ឬឥណ្ឌូចិន ជាដែនកណ្ដាលនៃអារ្យធម៌ ចំណែកដូចរ៉ូមដ៏ជាដែនកណ្ដាលនៃអារ្យធម៌ក្រិក ។ ទាំងនេះ ជាសមអាង ១ យ៉ាង ។

ពង្សាវតារនិងសេចក្ដីកត់ហេតុ — ក្នុងព្រះរាជពង្សាវតារក្រុងកម្ពុជាថា «ព្រះថោង អង្គមានជ័យមកអំពីឥណ្ឌាខាងត្បូង» ។ ពង្សាវតារភូមា [១] «ជាមនទីងខ្មែរជាបងប្អូនផងគ្នា ចុះមកអំពីឥណ្ឌាខាងត្បូងទាំងពីរពួកតែពួកមននផ្សាយមកមុនបន្តិច មននិងខ្មែរសុទ្ធតែមានប្រវត្តិដំណាលអំពីការសាងប្រាំមហានគររបស់ខ្លួន, ខ្មែរនោះធ្លាប់មានអំណាចផ្សាយទៅក្នុងដែនសុវណ្ណភូមិទាំងមូល ដរាបកន្លែងមកហើយក្នុងសម័យមួយ» ។ ពង្សាវតារចិនថា «អ្នកដែលតាំងប្រទេសខ្មែរដំបូង នាមហ្វូនទៀនមកពីឥណ្ឌា ចូលមកកាន់ប្រទេសនេះពីទិសខាងត្បូង» ។ ប្រវត្តិសាស្ត្រ

---

• ច្បាប់ដែលក្រុមព្រះនរាធិបប្រពន្ធពង្ស ប្រែចេញជាភាសាសៀម ។

សាកលថា[១] «ពួកឥណ្ឌាដែលចូលមកនោះ ដោយច្រើនមកអំពីខេត្រ ការណ៌ត សុទ្ធជាពួកដែលមានលោហិតព្រាហ្មណ៍ និងក្សត្រិយ៍លាយឡំ ផងដោយច្រើន ជាអ្នកកាន់ខ្លួនថាមានវណ្ណៈខ្ពស់» ។ គំនិតនេះជា សមគាន់ ១ យ៉ាង ។

## ហេតុដែលខ្មែរផ្សាយមក

តាំងពីក្រោយពុទ្ធកាលប្រមាណ ២០០ ឆ្នាំជាដើមមក ជនជាតិខ្មែរ បានផ្តើមផ្សាយមកក្នុងដែនសុវណ្ណភូមិ តែសន្សឹមផ្សាយទៅៗ មកជា ច្រើនលើក-ច្រើនឆ្នាំ ទើបបានតាំងឥស្សរភាពឡើងបាន ។ ហេតុដែល ខ្មែរផ្សាយមកនោះមាន ២ យ៉ាង គឺ ពួក១: មកដោយប៉ងដើម្បីរកស៊ីលក់ ដូរតាមធម្មតា ពួកនេះមកហើយត្រឡប់ទៅវិញក៏មាន នៅជាប់តែម្តង ក៏មាន ។ ពួក២: មកដោយភៀសសឹក ក្នុងពេលដែលមានសង្គ្រាមក្នុង ប្រទេស ពួកនេះមកម្តងៗ ច្រើននាក់ជបគ្នាកកហ៊ូនតែម្តង ។ ការ ភៀសសឹកបានមានឡើងក្នុងរជ្ជកាលព្រះបាទពិម្ពិសារ ព្រះរាជាមគធៈ (សោយរាជ្យក្នុងឆ្នាំ ព.ស. ២៥២) ដោយទ្រង់បានលើកទ័ពធំមកវាយ ឥណ្ឌាភាគខាងត្បូង រហូតចុះមកដល់ដែនទេព្រាស ។ តមក ក្នុង រជ្ជកាលព្រះបាទធម្មាសោក ចៅព្រះបាទពិម្ពិសារ (សោយរាជ្យ ព.ស. ២៧៦) បានស្តេចលើកទ័ពហូរមកវាយឥណ្ឌាភាគខាងត្បូង

១ របស់លោកហ្វ៊ីនូវិចិត្រកិទការ មើលត្រង់ភាគ ៩ ។

ទៀត ក៏យកពួកមកដល់ពលរដ្ឋ ។ សង្គ្រាមទាំងពីរលើកនេះ បានប៉ះពាល់មកលើប្រទេសកម្ពុជាយ៉ាងខ្លាំង ។ សង្គ្រាមលើកក្រោយនេះធំណាស់ ព្រោះក្នុងសំណាក់របស់ព្រះបាទធម្មាសោកថា អ្នកស្រុកត្រូវតែហានព្រះបាទធម្មាសោកសម្លាប់ចោលសិន ៗ ដែលត្រូវចាប់ជាឈ្លើយក៏ច្រើនណាស់ ។ ប្រទេសនោះៗ បានតស៊ូពេញទំហឹង តែពុំអាចនឹងទប់កម្លាំងសេនានុភាពនៃព្រះបាទធម្មាសោកបាន ក៏គោរពញ៉មចុះចាញ់ គ្រានោះ ប្រជារាស្ត្រទាំងនៅពុំបាន ក៏គេចេញអំពីមុខសឹកចូលទៅនៅបណ្ដើរមកក្នុងសុវណ្ណភូមិ ។ ក្នុងពេលសង្គ្រាមទាំងពីរលើកនេះ ប្រជាជនជាតិខ្មែរបានដោះខ្លួនចេញអំពីមុខសឹកជាច្រើន តែពុំបានមកទាំងអស់ទេ នៅសល់ក្នុងប្រទេសដើមជាច្រើនភាគ ។

ក្រោយមកទៀត ប្រមាណក្នុងឆ្នាំ ព.ស. ៦១០ ប្រទេសស្រុកស្ត្រឹនប្រទេសអន្ធ្រៈដែលនៅក្នុងឥណ្ឌាភាគខាងត្បូងជាមួយគ្នា កើតច្បាំងគ្នាឡើង សាហេតុសង្គ្រាមតពីរឿងសាសនា ហើយបណ្ដាលដល់ប្រទេសជិតខាង ។ ចំពោះគួបជប័ត្ត ដំបូងរវាងអន្ធ្រៈខាងប្រៀបជាង តមកចុងក្រោយ ខាងស្រុកស្ត្រត្រឡប់មានជ័យជំនះ ។ សង្គ្រាមគ្រានេះក៏មានអ្នកស្រុកតែងចៀសមុខសឹកចូលមកនៅក្នុងដែនសុវណ្ណភូមិជាច្រើនជួបមុន ៗ ។

ផ្លូវដែលផ្សាយមកក្នុងសុវណ្ណភូមិមាន ២ ផ្លូវ  គឺពួកខ្លះដើរផ្លូវគោក ដោយឆ្លងទន្លេមេគង្គ  មកឡើងត្រង់ឆ្នេរភាគកើតប្រទេសមន ។ ក្នុងពួកនេះ ពួកខ្លះគឺតាំងទីលំនៅក្នុងប្រទេសមន ក៏មាន ពួកខ្លះសន្សឹមដើរកាត់ប្រទេសមនមកខាងកើត  ស្វែងរកទីឲ្យខ្លួនតាំងទីលំនៅ នៅដោយអន្លើ ៗ រៀងរាយមកដល់នគរភ្នំ (កម្ពុជា) នេះ ក៏មាន ។ ពួកខ្លះជិះសំពៅចេញទៅទិសខាងត្បូង  សំដៅមកកោះសុមាត្រា  កោះជ្វា ចូលតាមច្រកមលាកា  ហើយបើកកាត់ត្រើយច្រាំងម៉ាលាយូ  បែរមុខទៀត  មកទិសឦសាន សំដៅចូលមកអាណាចក្រភ្នំពីខាងត្បូង បាន មកឡើងត្រង់ឈូងទន្លេបាសាក់នេះច្រើន  ជាងឡើងនៅទីដទៃ ។

លុះមកនៅច្រើនឡើង ៗ ប្រមាណក្នុងពុទ្ធសតវត្សទី ៧  ទើបបានចាប់ស្ថាបនាឥស្សរភាពឡើងក្នុងអាណាចក្រភ្នំ  សង្កត់លើឥស្សរភាពនគរភ្នំជាដំបូង  ក្រោយអំពីនោះមកក៏សន្សឹមៗ ផ្សាយឥទ្ធិពលចេញទៅទៀត  ដល់តែបានជាមហាប្រទេស  នៅក្នុងដែនសុវណ្ណភូមិ ដូចមានប្រាកដក្នុងប្រវត្តិសាស្ត្រទៅ ។

---

# សម័យនគរភ្នំ

ព. ស. ៦៩៣ - ១៣៤៣

ស្ថាបនាឯករាជ្យភាព

## ព្រះញាទកុមេរ

ប្រមាណ ព. ស. ៦៩៣ - ៧៤២ គ. ស. ១៥០ - ១៩៩

---

ផែនដីដែលជាប្រទេសកម្ពុជានេះ មុនដែលខ្មែរមកតាំងឥស្សរភាព នោះជារបស់ជាតិជ្វា បានតាំងឥស្សរភាពមកហើយ ប្រមាណ ១០០ ឆ្នាំ តាំងជាជាតិនៅកើតបាក់ទីបាណាម ហៅតាមភាសាខ្មែរថា នគរភ្នំ មានក្សត្រិយ៍គ្រប់គ្រងមក ៥ អង្គ, អង្គទី ៥ ជាក្សត្រីក្រមុំ ព្រះនាមហៅតាមសំដីចិនថា លីវយេ, ជាព្រះរាជិនីនគរនេះក្រោយបំផុត ។

ក្នុងរជ្ជសម័យនៃព្រះរាជិនីនេះ មានបុរស ១ នាក់ ជាតិជាព្រាហ្មណ៍ខ្មែរនាមកោណ្ឌញ្ញៈ ឬ កោណ្ឌិណ្យៈ ជាមហាបណ្ឌិតស្វាមី នៅអង្គកុមេរុជ្ឈក្នុងដែនឥណ្ឌាភាគទក្សិណ ព្រមដោយបក្ខពួកជាច្រើននាក់ សុទ្ធសឹងតែជាអ្នកមានសិល្បវិជ្ជាការជ្រៅជ្រះ បានរៀបរៀងស្បៀងអាហារ និងគ្រឿងសស្ត្រាវុធគ្រប់ខ្លួន ចុះសំពៅចេញចាកប្រទេសរបស់ខ្លួន បើកសំពៅឆ្ពោះសុមាត្រា ហើយបត់បែរសំពៅមកទៀងនគរភ្នំពីខាងត្បូង ចូលតាមឈូងទន្លេបាសាក់ ទៀងមកដល់នគរភ្នំ ។

តាមគតិនៃពួកនេះឃើញថា ទាក់ទងដោយប្រុងប្រៀបប្រហែលជាមាន បំណងនឹងមកក្រញាបយកនគរភ្នំ ទើបមានអាវុធជាប់នៅដៃមកផង ។

កាលស្ដេចកុលនគរភ្នំ សង្កេតឃើញគោលការណ៍ហាក់បានប្រែតអំពី ពួកបរទេសដែលភ្ជាប់ចូលមកស្រុកផង ដូច្នេះទើបបញ្ជាការឲ្យ ឲ្យទាហាន ១ ក្រុមចេញទៅប្រយាម ដោយគិតថា បើទុកបណ្ដោយឲ្យនៅ ទៅ អាចនឹងមានគ្រោះថ្នាក់ដល់ព្រះនគរ តែពួកគោណ្ឌញ្ញៈមិនព្រម ថយចេញទៅតាមបញ្ជា ទើបកើតជាសាហេតុតស៊ូគ្នាទៀតដោយអាវុធ តែមិនយូរប៉ុន្មាន ផលក្នុងវាចំផុតនៃការតស៊ូ គឺពួកគោណ្ឌញ្ញៈមាន ជ័យ ព្រះរាជធានីនគរភ្នំក៏គោងចុះញ៉ម ។

វីរបុរសគោណ្ឌញ្ញៈកាលបង្ក្រាបនគរភ្នំសម្រេចហើយ ក៏ត្រូវអ្នក នគរនេះទាំងពួករបស់ខ្លួន អញ្ជើញឲ្យឡើងគ្រងពិភពនគរភ្នំទៅ បានតាំងព្រះរាជធីតានគរភ្នំជាអគ្គមហេសីផង ប្រាកដព្រះនាមតាមព្រះ ភាគថា គោណ្ឌញ្ញៈតាមឈ្មោះប្រទេស ឬតាមឈ្មោះជាតិថា កុមេរុ ដែលពាក្យសាមញ្ញថា ព្រះថោង ។ ឯព្រះអគ្គមហេសីនោះ មិនមានអ្នក ណាស្គាល់ព្រះនាមជាផ្លាក់លាក់ទេ ក្នុងព្រះរាជពង្សាវតារក្រុងកម្ពុជាថា ព្រះនាម «នាគី» តែថាព្រះនាងនេះជានាគី ទៅវិញ ។ ចំណែកមក ក្រែងមានព្រះរាជបុត្រ ១ អង្គដែលប្រាកដព្រះនាមថា «ព្រះវីរវង្ស» ដែលក្នុងពង្សាវតារចិនហៅថា ប៉ុនប៉ុន ។

ការផែនដី: ក្រោយដែលបានគ្រងពិភពហើយ ព្រះបាទកុមារអគ្គរាជ បានទ្រង់សាងព្រះរាជវាំងជាថ្មី នៅជិតក្រុងចាស់នោះ ថ្មីសាងត្រួតលើក្រុងចាស់នោះឯង មុននឹងសាងបានស្តេចយាងទៅទតដល់ទីកន្លែង ដើម្បីនឹងរើសរកទីជយភូមិ ទ្រង់បានយកព្រះខ័ន លំពែងជ័យអំពីដៃរាជបុរោហិត ឈ្មោះអស្វត្ថាម៉ន (ជាបុត្ររបស់ព្រាហ្មណ៍ឈ្មោះទ្រោណ:) មកទ្រង់អធិដ្ឋានផ្សងហើយ ទើបទ្រង់ពួយព្រះលំពែងទៅ ដោយពេញទំហឹង ព្រះលំពែងជ័យទៅធ្លាក់ដោតនៅទី ១ ទ្រង់ក៏កំណត់យកទីនោះជាទីជយភូមិ ជាទីតាំងក្រុង ត្រាស់ឲ្យជាងសាងព្រះនគរឡើង ឲ្យនាមថា «វ្យាធបុរៈ» ។

ក្រៅអំពីការសាងក្រុងនេះ ទ្រង់បានចាត់ការទំនុកបម្រុងប្រជារាស្ត្រ ដោយផ្សាយចំណេះវិជ្ជាតាមបែបតម្រា ទាំងផ្លូវលោកទាំងផ្លូវធម៌ ឲ្យផ្សាយខ្ទរទៅគ្រប់មណ្ឌលព្រះរាជអាណាចក្រ តាមបាទៈនៃព្រះអង្គជាព្រះរាជម្ចាស់ផែនដី ប្រជានិករជាតិស្រុកកាយ កាលបានទទួលសេចក្តីសុខក្រោះអំពីព្រះអង្គដោយនានាប្រការផ្សេងៗហើយ ក៏មានសេចក្តីសោមនស្ស ព្រមទាំងសំដែងសេចក្តីស្វាមីភក្តិ និងសរសើរព្រះបារមីទូទៅ ។ ស្តេចស្ថិតនៅគ្រងរាជសម្បត្តិ ដល់ព្រះជន្ម ៩០ វស្សា ក៏សោយទិវង្គត ។

# សេចក្ដីអធិប្បាយខ្លះក្នុងរជ្ជកាលទី ១

ប្រវត្តិសាស្ត្រក្នុងរជ្ជកាលទី ១ នេះ ខ្វះស្រុកស្រាញហើយកំបាំងគំនិតរបស់អ្នកផងក៏មាន, ខ្លះបាត់ក្លាយទៅជារឿងព្រេងយ៉ាងអណ្ដែតអណ្ដូង តែក៏នៅមានបុគ្គលជាច្រើនរូប ជឿយ៉ាងស៊ប់ស្អួនថា ជារឿងប្រវត្តិសាស្ត្រពិតៗក៏មាន ។ រឿងទាំងនេះមិនទាន់ឃើញមានអ្នកណាវិនិច្ឆ័យទុកដោយត្រឹមត្រូវនៅឡើយ ។ ការដែលខ្ញុំរៀបរៀងព្រះរាជពង្សាវតារនោះ គិតឃើញជាមុនថា បើនឹងទុកបណ្ដោយឲ្យនៅដូច្នោះ នៅឃើញថា ល្អៀងពីសេចក្ដីពិតពេកណាស់ ទើបសូមអធិប្បាយបំភ្លឺខ្លះទុកក្នុងទីនេះដោយសង្ខេប ដើម្បីឲ្យអ្នកប្រាជ្ញប្រវត្តិសាស្ត្រជួយពិភាក្សានិងវិនិច្ឆ័យតទៅ ៈ

ព្រះបរមនាមនៃព្រះមហាក្សត្រិយ៍អង្គទី ១ ក្នុងព្រះរាជពង្សាវតារក្រុងកម្ពុជា[1]ថា ព្រះមហាក្សត្រិយ៍អង្គទី ១ នេះ មានព្រះជាតិជាក្សត្រិយ៍ ព្រះនាម "ព្រះថោង" ជារាជឱរសព្រះបាទអាទិច្ចវង្សនៅនគរឥន្ទ្រ-ប្រស្ថ ។ ច្បាប់ខ្លះថា ព្រះបរមនាម កុម្ពុ ដោយហៅតាមព្រះនាមព្រះរាជបិតា ។

សេចក្ដីពិត ព្រះមហាក្សត្រិយ៍អង្គអាទិករបស់ខ្មែរក្នុងប្រទេសនេះ មានជាតិជា "ព្រាហ្មណ៍" ព្រះនាមហៅតាមព្រះគោត្រថា

---

១ សំដៅយកពង្សាវតារស្ដេចកន ឬក្រាំងដែលមាននៅសព្វថ្ងៃនេះ ។

កោណ្ឌញ្ញៈ ឬ កោណ្ឌណ្យៈ ហៅតាមឈ្មោះជាតិ ឬហៅតាមឈ្មោះប្រទេសដើមថា កុមេរុ ។ ក្នុងពង្សាវតារចិនហៅព្រះនាមនៃព្រះមហាក្សត្រិយ៍អង្គនេះថា «ហ៊ុនទៀន» ។ ព្រះនាម ព្រះថោង ប្រែបានសេចក្តីថា «ព្រះអង្គមាស» ជាពាក្យលើកដំកើងតាមទំនៀម ដោយអធិប្បាយថា ដែលមានព្រះនាមថាព្រះអង្គមាស ដោយទ្រង់បានជាធំក្នុងស្រុកជ្រោយមាស ។ ព្រះនាម ហ៊ុនទៀន ជាភាសាចិន ប្រែបានសេចក្តីថា តែលើមេឃ (អធិរាជ ឬ បុស្សរាជ) ត្រូវនឹងពាក្យក្នុងបច្ចុប្បន្នថា ព្រះកែវហ្វា នេះគឺជាសេចក្តីហៅលើកដំកើង ដូចគ្នានឹងពាក្យថា ព្រះថោងដែរ គេគាប់ហៅ ព្រះអង្គមាស ឬព្រះកែវហ្វា ជំនួសព្រះបរមនាមបាន តែព្រះថោងអង្គនេះ មិនមែនជាក្សត្រិយ៍ដែលសាងនគរធំដូចមានពោលក្នុង ព.ក. ពង្សាវតារក្រុងកម្ពុជា នោះទេ ។

ព្រះនាមព្រះអគ្គមហេសីៈ ក្នុង ព.ក. ថា ព្រះអគ្គមហេសីព្រះថោង ព្រះនាម នាគវតី ជាធីតានាគរាជនៅឋានបាតាល ។

ព្រះថោងមានព្រះអគ្គមហេសីជានាងនាគមែនឬ ? យើងមិនបាច់ធ្វើឲ្យអ្នកប្រវត្តិសាស្ត្រជួយស្រាវជ្រាវទៀតទេ យើងអាចការកាត់ថា អគ្គមហេសីព្រះថោងឬព្រះបាទកុមេរុនោះ មានសញ្ជាតិជាមនុស្ស ហើយមានវណ្ណៈ ជាក្សត្រិយ៍សុទ្ធ ដូចពោលមកខាងដើម មិនមែនជាសត្វនាគតិរច្ឆាន ដូចមានពោលក្នុង ព.ក. នោះទេ ។ ព្រះនាមដូចម្តេច

ក្នុង ព. ក. ថា ណាកតី, ក្នុង ព. ច. (ពង្សាវតារចិន) ថា លិវយី ឬហៅ ឡីថា លិវ ៗ ពាក្យនេះជាភាសាចិន ប្រែបានសេចក្ដីថា ជាឈ្មោះដើមឈើ ១ យ៉ាង ឈ្មោះឈើនេះ ត្រូវនឹងពាក្យបារាំងថា Soule មានប្រភពដុះនៅតាមមាត់សមុទ្រ មានលក្ខណៈដើមនឹងស្លឹកសំប៉ុរទៀត, កន្លែងដើមដូចជង្គង់មនុស្ស ស្លឹកធ្លាល្អិតហើយវែងប្រមាណជាង ១ ហត្ថ ដូចសក់ក្បាលដែលរំសាយចេញ. កាលត្រូវខ្យល់សូម្បីខ្យល់តិចៗ ក៏រំភើយទៅមក ទំនងដូចសូរខ្សឹកៗ យ៉ាងអស្ចារ្យ ៗ ឈើនេះខ្មែរហៅដូចម្ដេច មិនអាចដឹងបាន តែមើលទៅឲ្យសមតាមហេតុផល គួរហៅ-ថា "ដើមសក់ក្រអូប" ព្រោះស្លឹកដូចសក់មនុស្ស ។ ព្រះកដិននគរខ្មែរប្រហែលជាមានព្រះនាមពិសេសថា "ព្រះនាងសក់ក្រអូប (ស៊ុគន្ធកេស-គន្ធារី) ដូច្នេះ មិនមែនជាណាគតី ព្រោះសមដោយរឿងបុរាណ ១ ថា មានស្ដេចក្សត្រិក្រមុំ ១ អង្គ ព្រះនាម នាងសក់ក្រអូប នៅក្នុងខែត្រត្រាំង (តាកែវ) ព្រះនាងនេះតាញ់កលនាយឈ្មួញសំពៅ ដោយនាយសំពៅឲ្យលេងមហោស្រពលើសំពៅក្នុងព្រែកមួយ ព្រះនាងសក់ក្រ-អូប ក៏ឡើងទៅចតលើសំពៅនោះ នាយសំពៅបានឲ្យគេដកយុថ្កាសន្សឹមៗថយចេញទៅ ទាល់តែទៅដល់កណ្ដាលសមុទ្រ ក៏យកព្រះនាងបាន ៗ រឿងនេះ គួរឲ្យសន្និដ្ឋានថាជារឿងព្រះបាទកោណ្ឌញ្ញៈនឹងព្រះនាងលិវយីតែម្ដង ៗ

នគរភ្នំ – ភ្នំ ជាភាសាខ្មែរ ក្នុងសិលាចារឹកគេសរសេរថា "វ្នំ" ចិនសរសេរ ទីនហៅតាមសំឡេងនេះដែរ តែមិនច្បាស់ ក្នុងដើមចិនសរសេរជា ភិ-យុ-ណាំ កាលចំឡងតៗមកក្លាយទៅជា ហ្វូណន,(១) ឬកាន់ហៅថា ហ្វូណន់, ជាឈ្មោះព្រះរាជធានី ឬតាំងជាឈ្មោះព្រះរាជអាណាចក្រខ្មែរក្នុងជាន់ដើម (នគរគោកធ្លក) ក្រុងនគរធំ (នៅសៀមរាប) មិនមែនជាបឋមនគរ ដូចក្នុង ព.ច. ឬដូចដែលអ្នកខ្លះយល់នោះទេ ។

ខ្មែរនឹងជ្វា – ក្រោយដែលព្រះបាទកុមេរុបានជាព្រះរាជាម្ចាស់ផែនដីអាណាចក្រភ្នំហើយ ជាតិខ្មែរនឹងជាតិជ្វាម្ចាស់ស្រុកដើម បានរួមគ្នាទៅជាជាតិ ១ ហៅថា កុមេរុ គឺជាខ្មែរសព្វថ្ងៃនេះ ឯលក្ខណៈរូបកាយទីងគាប្យមិនែជាតិទាំង ២ នេះ ផ្សេងគ្នាខ្លះ គឺលក្ខណៈរូបកាយខ្មែរក្នុងជាន់ដើមឯណោះ មិនដូចជាតាំងមិនដូចខ្មែរក្នុងសម័យនេះសោះទេ. ខ្មែរក្នុងជាន់ដើមរូបកាយច្រើនស្រងៗ ប្រមុះស្រួច សំបុរកាយខ្មៅស្រអែម យ៉ាងដែលហៅថា សំបុរផ្កាក្នុងបបចុខ ៗ ពួកប្រុស អ្នកដែលមានលោហិតជាព្រាហ្មណ៍ខ្មែរ ទុកសក់បួង អ្នកដែលជាខ្មែរសុទ្ធ កាត់សក់ ស្មៀតសំពត់ចងក្បិន ពួកស្រីទាំងអស់ ទុកសក់បួង ស្មៀតសំឡុយ ពាក់អាវខ្លីតែខ្លួន មានស្បែកទាត់តែក្រៅ ឬលចិត្តប្រដាប់ដោយគ្រឿងមាសគ្រឿងត្បូងច្រើនៗ ៗ និស្ស័យចិត្តជឿជាអ្នកអង់អាច មុះមុត

១ ហ្វូណន មិនមែន ភ្នំ ដូចអ្នកខ្លះយល់នោះទេ ។

គ្មានពុំស្លូតញុមចុះចាញ់សេចក្តីឡើយហាន ឬពួកបរបក្សដោយងាយ ជាពួកមានអារ្យធម៌ វប្បធម៌ និងសិល្បវិជ្ជាការទាំងពួង ខ្ពស់ជាងខាងនា ជាតិនៅដែនដីកោះនេះទាំងអស់ ។

ឯជាតិជ្វានោះ មានលក្ខណៈរូបរាងជាយ៉ាងមធ្យម សំបុរកាយសជ្រះ រូបល្អ ។ របៀបតែងកាយ ប្រុសកាត់សក់ ស្លៀកសំពត់ ។ ស្រីទុកសក់បួង ស្លៀកសំពត់ គ្រឿងប្រដាប់តែងកាយក្រៅពីសំពត់ ការនានាគឺជាសំខាន់ ។ និស្ស័យចិត្តថ្លើមជាអ្នកអត់ធន់ គួរដល់ការថែរទាំងពួង អារ្យធម៌នៅទន់ សិល្បវិជ្ជាការទាំងពួងមានបេះត្បាញសំពត់ ប្រើខ្លះដែរហើយ តែនៅជ្រោះជ្រោះ ពុំបានជាល្អហ្មត់ចត់នៅឡើយ ទីលំនៅសង់ឡើងដោយគ្រឿងឈើឬស្សីជាធម្មតា ជាខ្ទមតូចៗ ប្រើនចូលចិត្តអាស្រ័យនៅដោយខ្លួន ប៉ុន្តែប្រសប់ខាងផ្លូវជើងទឹក របរកស៊ី ធ្វើស្រែចំការ និងប្រើនប្រព្រឹត្តខាងផ្លូវនេសាទត្រីជារបរគាំទ្រ ។ ការកាន់សាសនាគឺជននោះពុំទាន់មាន មានតែការគោរពគោរពទេវតាក្សត្រជាសរណៈប្រចាំជីវិត ទើបមកបានទទួលគោរពបូជាសាសនាព្រាហ្មណ៍ និងព្រះពុទ្ធសាសនាខ្លះ តាមខ្មែរគឺវេលាដែលខ្មែរផ្សាយមកនៅក្នុងប្រទេសនេះជាច្រើនហើយ ។ តែទោះបីយ៉ាងណាក៏ដោយ ជាតិជ្វាមិនមានអារ្យធម៌សមគួរមកហើយ ទើបមកបាត់ឥស្សរភាពជាប្រទេសជាតិមកបាន ។

ប្រវត្តិសាស្ត្រប្រទេសឥណ្ឌា

ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម ប្រែរៀបរៀង

វគ្គទី ១

# អំពីសភាពនៃឥណ្ឌាសម័យបុរាណ

ផែនដីដ៏ធំទូលាយដែលជាទីស្ថិតនៃគណនាតារាងទាំងឡាយ ជាផែនកើតនៃសាសនានានា មានសាសនាព្រាហ្មណ៍និងពុទ្ធសាសនាជាដើម ជាកំណើតនៃរឿងរាមក្រុងជាទីដើមហៅថា «ភារតវគ្ស» ។ ឯឈ្មោះដែលហៅថាឥណ្ឌា ។ នេះ ដោយយល់ថា ប្រទេសនេះមានទន្លេសិន្ធុជាសំខាន់ ទើបមានឈ្មោះហៅម្យ៉ាងទៀតថា «សិន្ធុស្ថាន» តែសព្វថ្ងៃនេះ យើងនិយមហៅថា ឥណ្ឌា ឬស្រុកអាំងដ៍ តាមសំដីបារាំង ។ ចាប់អំពីដើមមក ផែនដីចំណែកនេះយើងហៅថា ជម្ពូទ្វីប ដូចមានរឿងរ៉ាវច្បាស់ក្នុងគម្ពីរដីការបស់យើងជាច្រើនអនេក ។

ឯសភាពរបស់ប្រទេសឥណ្ឌា យើងត្រូវតែពិនិត្យពិចារណាដោយម៉ត់ចត់ ព្រោះភូមិប្រទេសដែលមនុស្សតាំងអាស្រ័យនៅ រមែងជាគ្រឿងអប់រំចិត្តគំនិត ធ្វើឲ្យមនុស្សមានសភាពផ្សេងៗគ្នា ដូចជាពួកមនុស្សដែលនៅលើទីដីមានដីជាភក់ តែងមានជំនឿថា មនុស្សយើងតែស្លាប់ទៅតែងទៅតាមកំណើតជាដរាប ។ ឯពួកមនុស្សដែលនៅក្នុងទី

ក្រៀមក្រោះឥតមានដំណាំ ឬផលាផលអ្វីទេ តែងតែមានគំនិតគិតឃើញ ថា មនុស្សយើងស្លាប់ទៅសូន្យឥតកើតទៀតទេ ដូច្នេះជាដើម ។

ឥណ្ឌាជាជាតិដែលមានលក្ខណៈនិងការប្រព្រឹត្តខុសគ្នានឹងជនជាតិដទៃ ៗ មានប្រទេសអេស៊ីប្ដជាដើម ដូចយើងបានពោលរួចមកហើយ ។ ទុកជាឥណ្ឌាបានទទួលការប្រព្រឹត្តិក្រិកខ្លះ ដោយហេតុព្រះបាទអាលេក្សង់ដ្រមហាកដ្ឋាបក្រុងលុយចូលប្រទេសឥណ្ឌាមកហើយ តមក ជនជាតិក្រិកនិងជនជាតិឥណ្ឌាមានការប្រាស្រ័យទាក់ទងគ្នាជាច្រើនក៏ដោយ ឥណ្ឌាក៏នៅតែមានការប្រព្រឹត្តិរបស់ខ្លួនដោយឡែកជាច្រើន ដែលបានមកពីជាតិដទៃនោះគ្មានតិចទេ ព្រោះប្រទេសឥណ្ឌា មានភ្នំមានសមុទ្រជាកំពែងព័ទ្ធឡោមជុំវិញ ដូចជាភ្នំកាបូឡ, ភ្នំហិណ្ឌូកុស-ហិមាលយ៉, ជួរភ្នំក្ដី និងមហាសមុទ្រឥណ្ឌា របស់អស់នេះធ្វើឲ្យប្រទេសឥណ្ឌា ជាប្រទេសមួយនៅដោយឡែកដាច់ពីប្រទេសដទៃ ។

ចំណែកខាងក្នុងវត្ថុដែនដីប្រទេសឥណ្ឌានេះ គេបែងចែកជាពីរចំណែក ៗ មួយហៅថា មជ្ឈិមប្រទេសនៅខាងជើង ត្រង់ទំនាបទន្លេមេគង្គាឡើងទៅទល់នឹងជួរភ្នំហិមាលយ៉ , មួយចំណែកទៀតនៅខាងត្បូងហៅថាដេកាន់ ឬ បច្ចន្តជនបទ តាំងពីកាត់កណ្ដាលរបស់ឥណ្ឌាចុះមកដល់កោះលង្កា ។

ទឹកដីអាកាសរបស់ឥណ្ឌានោះ មិនសូវមានប្រទេសណាដូចទេ គឺនៅក្នុងតំបន់តែមួយ នៅក្នុងថ្ងៃតែមួយ អាចមានអាកាសរងាជាបំផុត ដល់មានហិមៈធ្លាក់ ហើយបែរជាក្តៅបំផុតស្ទើរតែទ្រាំពុំបានក៏មាន ។ អ្នកដែលធ្លាប់ឡើងទៅដល់កំពូលភ្នំហិមាល័យ ហើយត្រឡប់ចុះមកវិញ រមែងមានអាការថើងខ្លួនហាក់ដូចទៅនៅក្នុងស៊ីបេរី ហើយចេញពីស៊ីបេរី ក៏ដល់អាហ្វ្រិកតែម្តង គឺចេញពីរងាបំផុតក៏ដល់ក្តៅបំផុត ។ ជនជាតិឥណ្ឌាជាចំនួនច្រើនមិនបានទៅនៅលើភ្នំហិមាល័យ ប្រជាជននៅខាងក្រោមស្ទើរតែទាំងអស់ ដែលមានអាកាសក្តៅ ទើបគួរពោលថា ឥណ្ឌាជាប្រទេសក្តៅ ហើយក្តៅជាងប្រទេសឥណ្ឌូចិនយើងទៅទៀត ។

មនុស្សដែលនៅក្នុងប្រទេសក្តៅនិងប្រទេសរងា រមែងខុសគ្នាឆ្ងាយ គឺពួកជនដែលនៅក្នុងប្រទេសរងា ជាមនុស្សសព្រាប់ ឧឃាតមានមានៈ ព្យាយាមធ្វើការជានិច្ច ហើយចេះប្រែធម្មជាតិមកជាប្រយោជន៍ដល់ខ្លួន ប្រើធម្មជាតិជាគ្រឿងស្វះស្វែងចំណេះចេះដឹងសេចក្តីសុខសប្បាយ និងសេចក្តីស្តុកស្តម្ភដល់ខ្លួនផង ដូចជាពួកអឺរ៉ុប អាមេរិក ចិន ជប៉ុនជាដើម តែងមានលក្ខណៈជាអ្នកមានមានៈ ឧឃាតព្យាយាមតស៊ូនឹងទឹកដីអាកាស ដកកកាយរករ៉ែធាតុក្នុងផែនដីមកប្រើជាប្រយោជន៍បាន ទុកជាមានហិមៈនាំឲ្យត្រជាក់រងាជាបំផុតក៏នៅតែមានគំនិតចេះប្រើធម្មជាតិជាគ្រឿងកំសាន្តចិត្ត ដូចជាប្រណាំងរត់លេងកីឡាផ្សេងៗបាន ។

ឯពួកជនដែលនៅក្នុងប្រទេសក្តៅ ច្រើនតែទៅជាទាសានៃធម្មជាតិ មានមានៈព្យាយាមតិច មិនសូវមានគំនិតគិតខ្វាយខ្វល់ស្វែងរកសេចក្តីចំរើនទេ ។

ទុកជាឥណ្ឌាជាជាតិចាស់បុរាណដំណាច់ស្មើនឹងជាតិឯទៀត ៗ ដែលបានពោលមកហើយក៏ដោយ ប្រវត្តិសាស្ត្រដែលស្រាវជ្រាវរកបានក្នុងវេលានោះគឺមិនស្មើនឹងក្រិកឬរ៉ូមទេ ពោលគឺ សេចក្តីចំរើនរបស់ឥណ្ឌាក្នុងរយៈវេលា ៣ - ៤ ពាន់ឆ្នាំ មានការចំរើនតិចជាងសេចក្តីចំរើនរបស់ក្រិកនឹងរ៉ូម ក្នុងរយៈវេលាមិនដល់ ១ ពាន់ឆ្នាំ ។ តែចុះជាយ៉ាងណាក៏ដោយ នៅតែត្រូវថា ឥណ្ឌាជាប្រទេសចំរើនយ៉ាងក្រៃលែង ១ ក្នុងសម័យបុរាណ ហើយគង់ទ្រង់ហូតមកដល់សព្វថ្ងៃនេះ មិនលោយជាតិសាបសូន្យទៅ ។ អារ្យធម៌របស់ឥណ្ឌាជាមាតានៃអារ្យធម៌របស់ទ្វីបអាស៊ីទាំងមូល ។ ជនជាតិក្រិកជាទីកើតនៃអារ្យធម៌របស់អឺរ៉ុបយ៉ាងណា ឥណ្ឌាក៏ជាទីកើតនៃអារ្យធម៌របស់អាស៊ីយ៉ាងនោះដែរ ។ ភាសាសំដីរបស់ឥណ្ឌាផ្សាយចេញទៅហើយ ក្លាយជាភាសាសំដីរបស់នានាប្រទេស វិជ្ជាជាងរបស់ឥណ្ឌាជាគំរូបែបផែននៃការជាងរបស់ជាតិដទៃ ៗ ជាច្រើនជាតិ ត្រាតែមានអ្នកប្រាជ្ញប្រវត្តិសាស្ត្រខ្លះ ហៅឥណ្ឌាថាជា «ក្រិកនៃអាស៊ី» ។

បើយើងពិនិត្យតាមប្រវត្តិសាស្ត្រ នឹងឃើញថា ប្រទេសឥណ្ឌា មានលក្ខណៈប្លែកពីប្រទេសដទៃក្នុងសម័យបុរាណ គឺការផែនដីនិងការសាសនារមែងជាប់ទាក់ទងជាមួយគ្នាជាដរាប ដោយហេតុតែផែនដីឥណ្ឌាស្ទើរតែគ្រប់ៗអង្គ គោរពស្រ័យសាសនាជាគ្រឿងផ្សាយអំណាចនិងជំរើនព្រះកិត្តិយសរបស់ខ្លួន ដូច្នេះការរៀនប្រវត្តិសាស្ត្ររបស់ឥណ្ឌានោះ គេនឹងតែសិក្សាឲ្យស្គាល់ប្រវត្តិសាស្ត្រសាសនាព្រាហ្មណ៍ និងពុទ្ធសាសនាព្រមជាមួយគ្នាផង ។

ឯប្រជាជនជាតិឥណ្ឌានោះមាន ២ ពួកគឺ: ពួកអារិយកៈ ១ ពួក ពួកមិលក្ខៈ ១ ពួក ពួកក្រោយនេះជាម្ចាស់ស្រុកធ្លាប់នៅមកមុន ជនពួកនេះមានសំបុរខ្មៅហើយមានឈាមពូជជាតិណែគ្រោយផង ។ ឯពួកអារិយកៈជាពួកមានសំបុរស ដើមកំណើតនៅខាងអ៊ីរ៉ង់ឬអ៊ីរ៉ាក់ និងមេសូ-ប៉ូតាមី កាលប្រមាណ ៥.០០០ ឆ្នាំកន្លងមកហើយ ហើយមានខ្សែស្រឡាយលាយគ្នាជាច្រើនជាតិ គឺជាពូជមាសេដូនខ្លះ អារ៉ុបខ្លះ ទួរគីខ្លះ អាហ្វកានខ្លះ រូបរាងគ្នាជាពួកធំ មានរបរចិញ្ចឹមជីវិតដូចពួកហេប្រឺ គឺចិញ្ចឹមសត្វ ហើយនាំហ្វូងសត្វធ្វើដំណើរទៅ កាលបើបានជួបប្រទះនឹងភាគផែនដីដីជាតិមានស្មៅខៀវស្រស់នៅតំបន់ណា ក៏តាំងទីកន្លែងសំចតនៅដំបន់នោះ កាលបើអស់ផលាផលសម្រាប់ចិញ្ចឹមគ្នានិងចិញ្ចឹមសត្វហើយ ក៏លើកចេញទៅរកកន្លែងដីជាតិថ្មីទៀត ។

ជនពួកនេះស្ទាត់ខាងការជាងឈើ ជាការដែលមនុស្សប៉ុកណាដទៃទៀត មិនទាន់យកចិត្តទុកដាក់ ។ មានអ្នកប្រាជ្ញប្រវត្តិសាស្ត្រខ្លះពោលថា ជាតិឥណ្ឌៀជាមនុស្សជាតិដំបូងដែលចេះធ្វើកង់រទេះ ជាគ្រឿងជំនួយនាំឲ្យធ្វើដំណើរបានរហ័សបន្តិច និងជួយកំឡាំងបានជាច្រើន ជាការដែលជាតិឥណ្ឌៀឈ្លាស់ថា ខ្លួនបានស្ទុះឡើងដល់ថ្នាក់សេចក្តីចំរើន ហេតុដូច្នោះហើយ បានជាកង់រថឬរទេះនេះទៅជាគ្រឿងសំគាល់នៃសីលធម៌, បញ្ជាក់របៀបបែបផែននៃសេចក្តីចំរើនរបស់ឥណ្ឌៀ ។ សូម្បីតែក្នុងព្រះពុទ្ធសាសនាក៏នៅប្រកាន់តាមទំនងនេះដែរ ដូចជាគ្រឿងសំគាល់ព្រះធម្មចក្រក៏ធ្វើជារូបកង់រថ ហើយវិន្យធម៌ ៤ ប្រការរបស់ព្រះពុទ្ធជាម្ចាស់ក៏ហៅថា ចក្ក ៤ ដែរ (គឺកង់ទាំង ៤ ដែលវិលទៅកាន់សេចក្តីចំរើន) ។ ពួកដែលលើកគ្រួសារចេញពីស្រុកអ៊ីរ៉ង់ និងមេសូប៉ូតាមីនោះ ជាវេលារាប់ទាំងពាន់ៗឆ្នាំ ហើយចេញតៗគ្នាមកជាច្រើនជំណមនុស្ស ។ ចំណែកឯពួកមិលក្ខៈ ដែលជាម្ចាស់ស្រុកដើមរបស់ឥណ្ឌៀនោះ ក៏នាំគ្នាតទាំងតស៊ូប្រឆាំងតទល់នឹងពួកដែលលុកចូលស្រុកទេសរបស់ខ្លួនយ៉ាងម៉ឺងម៉ាត់ តែនៅទីបំផុតម្ចាស់ស្រុកបរាជ័យ ពួកដែលលុកលុយចូលមកក៏តាំងទីនៅនឹងខ្ពង់ខ្ពស់ ។ នៅទីទំនាបត្រង់ភាគកណ្តាលនៃទន្លេសិន្ធុ និងតំបន់ច្រោះទន្លេយមុនា និងទន្លេគង្គា ។ ពួកនេះហៅ

ពួកខ្លួនថា អារិយកៈ ហៅភូមិប្រទេសដែលខ្លួននៅតាំងនៅថា មជ្ឈិមប្រទេស ។ ឯម្ចាស់ស្រុកដើម ដែលខ្លួនដណ្ដើមយកដែនដីបានមក នោះហៅថា មិលក្ខៈ (ប្រែថា មនុស្សព្រៃ) ឯស្រុកដែលពួកមិលក្ខៈនៅតាំងទីកន្លែងផ្សេងទៀតជាដែនដីធំសំបើមដែរ ក៏ហៅថា ដែនកាន់ឬបច្ចន្ត-ជនបទ (ប្រែថា ស្រុកចុងដែន) ។ ពួកអារិយកៈនោះប្រកាន់ខ្លួនថា មានសេចក្ដីចំរើន ទាំងចំណេះចេះដឹងច្រើនជាងម្ចាស់ស្រុកដើម ។ ឯការលុកលុយយកដែនដីនេះ មានការប្រយុទ្ធតទល់គ្នារវាងពួកដែលលុកចូលមកនឹងម្ចាស់ស្រុកជាច្រើនលើកច្រើនគ្រា ហើយពួកដែលលុកចូលមកមានជ័យជំនះ បានដាក់ឈ្មោះហៅម្ចាស់ស្រុកម្យ៉ាងទៀតថា «ទាសៈ» កាលដើមគ្រាន់តែសំដៅសេចក្ដីថា «សត្រូវ» មិនមែនប្រែថា ខ្ញុំកំដរដូចយ៉ាងក្រោយៗនេះទេ លុះពួកដែលលុកចូលស្រុកមានជ័យជំនះហើយចាប់ម្ចាស់ស្រុកទៅធ្វើជាឈ្លើយ ទើបពាក្យថា «ទាសៈ» នេះក្លាយទៅជាថាមនុស្សបម្រើខ្ញុំកំដរទៅ ។

យើងបានពោលមកហើយថា ការគ្រប់គ្រងដែនដីរបស់ឥណ្ឌានោះ វែងជាប់ទាក់ទងគ្នានឹងលទ្ធិសាសនាជាដរាប ដូច្នេះ ការរៀនប្រវត្តិសាស្ត្រឥណ្ឌា ទើបយើងត្រូវចាប់ផ្ដើមសិក្សាសាសនាតែម្ដង ។

យើងបានដឹងហើយថា សាសនាដែលចាស់បំផុត របស់ឥណ្ឌាគឺសាសនាព្រាហ្មណ៍ មូលហេតុនៃសាសនាព្រាហ្មណ៍ គឺពួកដែល

លុកលុយចូលមកនោះឯង បាននាំយកជំនឿការប្រកាន់កប់គានចូលមកក្រើផង ឯការគោរពកប់ខ្មោចមនុស្សដែលបដើរត្រឡប់ទៅកាន់ទិសឆ្ងាយៗ ថែបនេះ គឺមិនឃើញមានអ្វីក្រៅពីទឹកដី មេឃ អាកាស ទើបពួកនេះបង្កើតឲ្យមានព្រះជាច្រើនអង្គផ្សេងៗ គ្នាជាទីគោរពរបស់ខ្លួន គឺព្រះឥន្ទ្រជាម្ចាស់ឋានសួគ៌ ម្ចាស់អាកាស និងម្ចាស់ផ្គរ, ព្រះអគ្និជាព្រះនៃភ្លើង, ព្រះសុរិយៈ គឺព្រះអាទិត្យ, ព្រះវរុណៈ គឺព្រះនៃភ្លៀង, ព្រះឧជៈ គឺព្រះនៃពន្លឺប្រាក់ (ថ្ងៃរះ), អស្វិន គឺព្រះនៃពន្លឺមាស (ថ្ងៃលិច), រុទ្រៈ គឺព្រះនៃខ្យល់ព្យុះ, ល។; គឺពួកទេវតាជាបរិវារ ។

មួយវិញទៀត សាសនាព្រាហ្មណ៍នេះ គេគោរពកប់គានព្រហ្មជាធំ តែការគោរពព្រះព្រហ្មនេះ មិនមែនចាប់តាំងពីដំបូងមកទេ គឺជាន់ដើមមានតែពួកព្រះផ្សេងៗ ដែលពោលមកហើយប៉ុណ្ណោះ តមកទើបកើតគំនិតគិតឃើញជាថ្មីទៀតថា បុះដួងអាទិត្យដួងចន្ទ្រ មេឃដី ទឹកតែឯទៀតៗនោះ តើអ្នកណាជាអ្នកតសាងឡើង ។ របស់ទាំងនេះមិនមែនកើតឯងទេ គង់មានអ្នកកសាងឡើងជាប្រាកដ ដោយហេតុនេះហើយ ទើបពួកព្រាហ្មណ៍បញ្ញត្តិឲ្យមានព្រះ ១ អង្គទៀតហៅថា ព្រះព្រហ្មៗជាអ្នកសាងលោកព្រមទាំងមនុស្សសត្វទាំងពួងផង តែព្រះព្រហ្មកើតឯង ឥតនរណាកសាងឡើយ ។

សាសនាព្រាហ្មណ៍ មានគម្ពីរដ៏សក្តិសិទ្ធិរបស់គេហៅថា «វេទ» គម្ពីរនេះគេកាន់ថា បានទទួលមកពីព្រះទស្សព្រហ្ម មិនមែនជាគម្ពីររបស់គាត់តែងឡើងដោយវិស័យរបស់មនុស្សទេ ។ ដំបូង គម្ពីរនេះគេបែងចែកចេញជា ៣ ផ្នែក គឺៈ ឫគ្វេទ ១ យជុរវេទ ១ សាមវេទ ១ តមក បានថែម ១ ផ្នែកទៀតហៅថា អថព៌វេទ សុទ្ធជាគាថាអាគម ហៅខ្មោចបិសាច ឲ្យជួយដោះទុក្ខព្រោះថ្នាក់អន្តរាយ ឬជាពាក្យបណ្តាសា ។

សាសនាព្រាហ្មណ៍នេះ ជាមូលហេតុនៃការបែងវណ្ណៈគឺជាន់ថ្នាក់របស់មនុស្ស ក្នុង(ប្រទេសឥណ្ឌា) សម័យបុរាណ ។

ក្នុងគម្ពីរឫគ្វេទពោលទុកថា មនុស្សយើងនេះព្រះព្រហ្មបានកសាងឡើងអំពីកាគរៀង ៗ ក្នុងកាយរបស់ព្រះព្រហ្មទ្រង់ឯង គឺយកមាត់ព្រហ្មមកសាងជាព្រាហ្មណ៍ យកដៃព្រហ្មមកសាងជាក្សត្រ យកភ្លៅព្រហ្មមកសាងជាពាណិជ ហើយយកជើងមកសាងជាកម្មករ ដោយហេតុនេះ ទើបពួកព្រាហ្មណ៍ចាត់ជាវណ្ណៈខ្ពង់ខ្ពស់បំផុត ហើយជាម្ចាស់សាសនាធ្វើការផ្សាយបដិម្ហានដល់មនុស្សទាំងពួង ៗ អ្វី ៗ ដែលព្រាហ្មណ៍ពោលទុកមកសុទ្ធតែចេញមកអំពីព្រហ្ម ព្រោះព្រាហ្មណ៍បានកំណើតមកអំពីព្រះទស្សព្រហ្មស្រាប់ហើយ ។ លុះមកដល់សម័យពុទ្ធកាល ក្សត្រត្រឡប់ជាមានអំណាចចម្រើនឡើង សម័យនោះក្សត្រខ្ពង់ខ្ពស់ជាង

ព្រាហ្មណ៍ទៅទៀត ។ ពួកជនជាតិខ្ពស់វែងប្រកាន់ខ្លួនមានមានៈ មិនព្រមរៀបការជាស្វាមីភរិយានឹងជនជាតិទាបជាងទេ ដូចពួកព្រាហ្មណ៍តែងរៀបការតែក្នុងពួកព្រាហ្មណ៍ផងគ្នា មានកូនមកជាព្រាហ្មណ៍តែម្តង មិនបាច់ទៅបួសទេ ។

កាលពីសម័យបុរាណនោះ ការចាត់ចែងលំដាប់ជាន់របស់មនុស្ស មិនមែនគ្រាន់តែចាត់ឲ្យមានជាន់មានថ្នាក់ប៉ុណ្ណោះទេ គឺនៅមានបញ្ញត្តិឲ្យតែងខ្លួនប្រើពណ៌សំពត់ខុសៗគ្នាទៀតផង គឺពួកព្រាហ្មណ៍ប្រើសំពត់ពណ៌ស ក្សត្រប្រើសំពត់ពណ៌ក្រហម វេស្សៈ (ពាណិជ) ប្រើសំពត់ពណ៌លឿង សូទ្រៈ (កម្មករ) ប្រើសំពត់ពណ៌ខ្មៅ បានជាគេហៅជាន់ថ្នាក់របស់មនុស្សអស់នេះថា «វណ្ណៈ» ដែលប្រែថា ពណ៌ ។ តែចួនកាលមានផ្លាស់ប្តូរវណ្ណៈខ្លះដែរ ដូចជាព្រាហ្មណ៍ វេស្សៈ ឬសូទ្រៈ កាលមានបុណ្យវាសនាឡើងក៏អាចឡើងជាក្សត្របាន តែក្សត្រវេស្សៈ ឬសូទ្រៈ ទុកជាចេះគម្ពីរវេទច្រើនយ៉ាងណា ឬធ្វើខ្លួនឲ្យវិសេសដូចម្តេចក៏ដោយ ចង់ក្លាយទៅជាព្រាហ្មណ៍មិនបានឡើយ ព្រោះវណ្ណៈព្រាហ្មណ៍ជាវណ្ណៈស័ក្តិសិទ្ធិ ។

សាសនាព្រាហ្មណ៍នេះ ទុកជាមានទាំងដម្បូន្មានគ្រប់ល្អយ៉ាងណាក៏ដោយ ក៏ត្រូវទុកជាសាសនាហួសសម័យបុរាណ ជាងសាសនានានាទាំងអស់ក្នុងលោក ហើយមានអាយុវែងយូរមកដល់សព្វថ្ងៃនេះ ។

ទៅប្រទេសឥណ្ឌា ទុកជាមានសាសនាផ្សេងៗកើតឡើង ក៏មិនអាចលុបលាងលទ្ធិសាសនាព្រាហ្មណ៍ ឲ្យបាត់សាបសូន្យពីឥណ្ឌាទៅបានឡើយ ។

លុះដំណើរកាលតមកមុនព្រះពុទ្ធសករាជ ៨០ ឆ្នាំ ព្រះមហាបុរសរ័តន៍ បានមកចាប់កំណើតក្នុងលោកនេះ ហើយទ្រង់ជាវរមគ្រូនៃលោក ទ្រង់បានបង្កើតលទ្ធិសាសនាថ្មីមួយឡើង ដែលជាសាសនាធំបំផុតក្នុងលោក គឺព្រះពុទ្ធសាសនា ឯប្រវត្តិនិងសាសនធម៌របស់សាសនានេះ យើងគ្រប់គ្នាជាពុទ្ធសាសនិកជនបានដឹងរឿងរ៉ាវច្បាស់លាស់ហើយ មិនបាច់អធិប្បាយពន្យល់ដោយពិស្តារក្នុងទីនេះទេ តែសាសនានេះមានសេចក្ដីសំខាន់ក្នុងប្រវត្តិសាស្ត្រឥណ្ឌា ដូចមានសេចក្ដីសរសេរតទៅខាងមុខ ។

កាលសម័យព្រះពុទ្ធជាម្ចាស់មានព្រះជន្មនៅឡើយនោះ មានគណាចារ្យម្នាក់ទៀតហៅថា មហាវីរៈនាដបុត្រ អាយុតិចជាងព្រះពុទ្ធជាម្ចាស់ ១៨ ឆ្នាំ តែអនិច្ចកម្មទៅក្រោយព្រះពុទ្ធបរិនិព្វាន ១០ ឆ្នាំ គឺថាគណាចារ្យនេះមានអាយុបាន ៧២ ឆ្នាំទើបអនិច្ចកម្ម លោកនេះកើតនៅស្រុកវេសាលី ; កាលលោកអាយុ ៤០ ឆ្នាំ ហើយបានចាប់ផ្ដើមធ្វើជាគណាចារ្យ ហើយត្រាចចរទៅប្រដៅទូន្មានលទ្ធិរបស់ខ្លួនក្នុងដែនមគធៈ វិទេហៈ បានតាំងជាសាសនាឡើងដែលបានគេហៅថា ជៃនិស្ម៍

ដែលចេញមកពីពាក្យថា ជិនៈ ប្រែថា ការឈ្នះខ្លួនឯង, លោកនេះ អនិច្ចកម្មទៅស្រុកបាក់ ដែនមល្លៈ (នៅដែនជាមួយនឹងព្រះពុទ្ធបរិនិព្វាន នៃស្រុកដោយឡែកពីគ្នា គឺព្រះពុទ្ធបរិនិព្វានទៅស្រុកកុសិនារា ) មាន សេចក្តីជំណាលថា វេលាដែលលោកសាស្តានេះអនិច្ចកម្មទៅ មាន សាវកច្រើនជាង ១ ហ្មឺន ៤ ពាន់នាក់ ។ ឯគោលធម៌សំខាន់ៗ ក្នុង សាសនានេះ ក៏ប្រហែលគ្នានឹងពុទ្ធសាសនាដែរ ហើយមានការជជែង គ្នានឹងយូរយោបល់គ្នាទៅវិញទៅមក ហើយជួយគ្នាស៊ប់លុបលាងលទ្ធិ សាសនាព្រាហ្មណ៍ តែការប្រណាំងប្រជែងប្រកួតប្រណាំងគ្នាក៏មាន ខ្លះដែរ ដូចជាសិស្សខ្លះរបស់មហាវីរៈ ៗ បញ្ជូនឲ្យទៅគាល់ព្រះពុទ្ធជា ម្ចាស់ដើម្បីសាកសួរប្រស្នាប្រការខ្លះ ពេលបានស្តាប់ព្រះពុទ្ធទូន្មានក៏កើត សេចក្តីជ្រះថ្លា សូមបួសក្នុងព្រះពុទ្ធសាសនា មិនបានត្រឡប់ទៅរក មហាវីរៈវិញទៀតក៏មាន ។

តាមយោបល់របស់អ្នកប្រាជ្ញប្រវត្តិសាស្ត្រ ក្នុងសម័យនេះ ប្រទេស ឥណ្ឌាបានគាំទ្រខ្លួនឃ្លាប់ខ្លួនមកហើយ ប្រហែល ២.០០០ ឆ្នាំមុនពុទ្ធកាល តែពង្សាវតារដែលល្បីជាគោលហេតុបាននោះ តាំងពីត្រឹមពុទ្ធកាល ចុះមក ជួមុនពុទ្ធកាលបន្តិចបន្តួច ហើយប្រាកដជាបែកខ្ញែកគ្នាជាច្រើន គណបក្ស ។

ក្នុងភាគខាងជើង មានភ្នំហេមវណ្ណ ឬភ្នំហិមាលយ៉ា ជាកំពែងខាងរវាងឥណ្ឌា និងទីបេត ឯភ្នំហិមាលយ៉ាដែលហៅថា ភ្នំហិមពាន្ត ជាភ្នំខ្ពស់បំផុតក្នុងលោក កំពូលដែលខ្ពស់បំផុតមានកំពស់ជិត ៩ គីឡូម៉ែត្រ កំពូលដែលហៅឯវ៉ឺរែស្ត៍ កំពស់ ៨ គីឡូម៉ែត្រកន្លះ ។ ទន្លេសិន្ធុនៅទិសខាងលិចឆៀងខាងជើង ដើមទឹកចេញពីដែនទីបេតហូរកាត់ជួរភ្នំមកខាងស្រុកតក្កសិលា ហើយហូរទៅធ្លាក់មហាសមុទ្រឥណ្ឌា ទន្លេនេះកាលសម័យពុទ្ធកាលល្បីខាងមានពូជសេះល្អ គឺសេះដែលកើតនៅជិតទន្លេនេះ ជាសេះល្អវិសេសចាត់ជាសេះលេខ ១ ។ តែកាលបើយើងពិនិត្យមើលផែនទីទៅ ទើបមិនបាច់មានសេចក្ដីងឿងឆ្ងល់ទេ ព្រោះផែនដីខាងជើងទន្លេសិន្ធុនេះ នៅជិតប្រទេសពែរ្សនិងអារ៉ាប់ ប្រទេសទាំងពីរនេះ ធ្លាប់មានពូជសេះល្អវិសេសរហូតមកដល់សព្វថ្ងៃនេះ ។ ដូច្នេះ ដែលហៅថា សេះសិន្ធព គឺមានពូជពង្សមកពីសេះអារ៉ាប់ហ្នឹងឯង ។ គន្ធាររដ្ឋ (ឥណ្ឌា) នៅទិសខាងលិចឆៀងខាងជើងនេះ នៅជាប់នឹងស្រុកដែលពួកពែរ្សកាន់កាប់ម្ដងម្កាល មុន (ត្រាន់តែចូលទៅក្រឥណ្ឌា) ក៏ចូលក្នុងដែនគន្ធារៈ មានស្រុកតក្កសិលាជាទីក្រុង ។ ឯស្រុកតក្កសិលានេះ ជាស្រុកដែលចំរុងរឿងដោយសិល្បសាស្ត្រនិងគ្រូបាអាចារ្យ មានដែនឯទៀត ៗ ផ្ញើកូនចៅទៅរៀនសូត្រជាចំនួនច្រើន ទាំងកូនក្សត្រនិងកូនសេដ្ឋីគហបតី សិស្សណាដែលបានសិក្សា

វិជ្ជាការពីសំណាក់អាចារ្យទិសាបាមោក្ខ ហើយមានមុខមាត់នឹងកេរ្តិ៍ឈ្មោះ ល្បីល្បាញ ជាទីពឹងពាក់របស់ញាតិមិត្រទាំងអ្នកនគរ មានទំនងដូច និស្សិតបានសិក្សាស្រេចបវិជ្ជាចំណេះពីទ្វីបអឺរ៉ុប ក្នុងសម័យបច្ចុប្បន្ន ។ ណាដែលស្រុកតក្កសិលាជាទីប្រជុំនៃសិល្បសាស្ត្រនោះ ក៏មិនជាឆ្ងាយ ប៉ុន្មានទេ ដ្បិតស្រុកនេះនៅជិតប្រទេសប៉ើរ្ស ដែលមានសេចក្តី ចំរើនរុងរឿងមកយូរលង់ហើយ ទើបអាចផ្លាស់ប្តូរសេចក្តីចេះដឹងដល់ គ្នានឹងគ្នាបានដោយងាយ ៗ តពីនោះមកទិសខាងកើត គឺដែនកស្មីរៈ ក្នុងចំណែកនេះ ទន្លេសិន្ធុបានញែកបែកចេញទៅជាច្រើនផ្លូវ មានឈ្មោះ ផ្សេងៗគ្នា តមកទៀតក៏ដល់ទន្លេយមុនា ហើយនៅចន្លោះទន្លេយមុនា នឹងទន្លេគង្គានោះ មានអាណាចក្រ ១ ហៅថា កុរុ មានស្រុកឥន្ទបត្តជាទី ក្រុង លុះចូលទន្លេគង្គាមកក៏ដល់អាណាចក្របញ្ចាលៈ មានស្រុកកម្បិល្លៈ ជាទីក្រុង ដល់ឡើងទៅលើបន្តិចក៏ចូលក្នុងខែត្រដែនកោសល ដែល ក្នុងជាន់បុរាណហៅថា អយោធ្យា ជាទីក្រុង ហើយជាស្រុកកំណើតនៃ រឿងរាមកេរ្តិ៍ ក្រុងអយោធ្យាជាទីក្រុងរបស់ព្រះរាម ៗ តែតមកដល់ សម័យពុទ្ធកាល ស្រុកសាវត្ថីដែលនៅខាងជើងឡើងទៅលើ ជិតជើង ភ្នំហិមាល័យ ជាទីក្រុងរបស់ដែនកោសល ក្រោមកោសលចុះមកគឺដែន កាសី ដែលមានស្រុកពារាណសីជាទីក្រុង ។ នៅខាងកើតកោសល

គឺដែនវិទេហៈ ដែលមានស្រុកមិថិលាជាទីក្រុង ខាងជើងក្រុងមិថិលា ឡើងទៅ ទើបដល់ស្រុកកបិលពស្តុជាស្រុកកំណើតនៃព្រះពុទ្ធជាម្ចាស់ ខាងក្រោមដែនវិទេហៈនិងកោសលចុះមក គឺដែនមគធៈ ជាដែនដែលព្រះពុទ្ធជាម្ចាស់ទ្រង់ប្រកាសព្រះពុទ្ធសាសនាជាដំបូង ។ ព្រោះនេះ យើងពិនិត្យមើលទៅទិសខាងកើតនិងពិនិត្យមើលពីខាងជើងចុះមកខាងត្បូង នឹងឃើញក្រុងកបិលពស្តុ កុសិនារា មិថិលា វេសាលី ចុះដល់បុក្រ ខនិងរាជគ្រឹះ រៀងគ្នាជាលំដាប់ពីជើងមកត្បូង ។

៦វិធីការគ្រប់គ្រងអាណាចក្រអស់នេះ មានច្រើនវិធី គឺអាណា-ចក្រខ្លះ មានព្រះរាជាសោយរាជ្យបកផ្ដាច់ការដែលជាប់ស្រេច ដូចដែនមគធៈ និងកោសល អាណាចក្រខ្លះ មានវិធីការគ្រប់គ្រងដោយសាមគ្គីធម៌ វិធីនេះ គឺមានក្សត្រច្រើនអង្គ មានអំណាចប្រហែលៗ គ្នា គ្រប់គ្រងស្រុកជាមួយគ្នា កាលបើមានកិច្ចការកើតឡើងដូចសង្គ្រាមជាដើម ក្សត្រអស់នោះ ក៏ប្រជុំប្រឹក្សាគ្នានិងជួយគ្នាតាំងតែនកិច្ចការតាមសមគួរ ។ វិធីនេះ ស្មើតាក់តាការបៀបចំនួនពីជាតិដទៃ ៗ ក្នុងសម័យបុរាណទាំងអស់ ។

អាណាចក្រទាំងឡាយរបស់ឥណ្ឌា ដែលបែងចែកគ្នាជាច្រើនផ្សេងៗ ក្នុងសម័យពុទ្ធកាល មានអាណាចក្រ ៦ ដែលមានអំណាចច្រើន

ជាទីនេះ គឺអាណាចក្រកោសលទីក្រុងហៅថា សាវត្ថី ព្រះរាជាដែលសោយរាជសម្បត្តិព្រះនាមបសេនទិ ជាសហជាតិនឹងព្រះពុទ្ធជាម្ចាស់ ១ អាណាចក្រមួយទៀតគឺ មគធៈ ទីក្រុងហៅថា រាជគ្រឹះ នេះ មានសេចក្តីដំណាលថា ព្រះបាទសុសុនាគៈ ក្សត្រគង់ក្រុងពារាណសីជាមុន កសាងឡើងមុនព្រះពុទ្ធសករាជ ៩៩ ឆ្នាំ ដូច្នេះ ក្សត្រដែលគង់ក្រុងនេះ ទើបហៅថារាជវង្ស សុសុនាគៈ លុះមកដល់សម័យពុទ្ធកាល ក្សត្រគង់រាជសម្បត្តិជាជំនាន់តវង្សត្រាមកដល់អង្គទី ៥ ។ នេះ ទ្រង់ព្រះនាមព្រះបាទពិម្ពិសារ ជាបឋមក្សត្រដែលទ្រង់កប់អានព្រះពុទ្ធសាសនា បានគ្រងដែនមគធៈជាវេលា ២៩ ឆ្នាំ ទើបទ្រង់ទិវង្គតទៅ កាល ១៦ ឆ្នាំមុនព្រះពុទ្ធជាម្ចាស់បរិនិព្វាន ។ ទើបព្រះរាជឱរសព្រះនាមអជាតសត្រូវ ទ្រង់ឡើងគ្រងរាជសម្បត្តិជាជំនាន់តមក ហើយច្បាំងយកដែនកោសល ពង្រីកអាណាខេត្តរហូតដល់ទំនាបទន្លេគង្គា តពីនោះមកដែនមគធក៏មានអំណាចធំក្រៃលែងតែម្នាក់ឯងក្នុងឥណ្ឌា កាលព្រះពុទ្ធសករាជកន្លងទៅបាន ១១ ឆ្នាំ ព្រះបាទអជាតសត្រូវ ទ្រង់ផ្លាស់ទីក្រុងរាជគ្រឹះទៅតាំងឯក្រុងបាតលីបុត្រវិញ ទ្រង់គ្រងដែនមគធៈ ជាវេលា ៣២ ឆ្នាំ ទើបទ្រង់ទិវង្គត ក្រោយព្រះពុទ្ធបរិនិព្វាន ១៧ ឆ្នាំ ។ (មានត)

# លោកភ៉យ-ប៊ុកប្រី, ឃុនសុវត្ថិវេទ៍ យូរ-អ៊ុនពិនិត្យកែ

(តមក)

២៨- ចូរគន់សេចក្ដីអត់ធន់ចំពោះលំបាក ចាត់ជាសង្គ្រាម, បើឯង ច្បាំងចាញ់ ១ ដង ២ ដង ឬច្រើនដង ត្រូវឯងចូលច្បាំងជាថ្មី កុំអាល ទៅខានមុខ គង់មានថ្ងៃណាមួយ ឯងនឹងមានជោគជ័យពុំខាន ។

អេពិកតែត

កើតទុក្ខដោយសារតោរស៊ូទ្រាំ   ស៊ូរងផលកម្មផ្ដល់វេទនា
លោកទុកជាសង្គ្រាមរបួ   តែងមានតពល់គ្នានាលោកនេះ ។
សង្គ្រាមនោះអ្នកត្រូវតតាំង   ដោយព្យាយាមខ្លាំងរៀនចំណេះ
ឬក្លើតារសារតាមគម្រែះ   ច្រើនដងគង់ល្បះល្បើចទុក្ខា ។»

២៩- បណ្ឌិតប្រកាន់ថា ការប្រសើរតែសេចក្ដីអត់ធន់ចំពោះអំពើ ទុច្ចរិតដែលគេធ្វើមកលើខ្លួន កុំឲ្យតែខ្លួនប្រព្រឹត្តអំពើទុច្ចរិតទៅលើគេ ។

ប្លាតុង

«ខន្តីអំណត់ ទំសង្កត់មិនក្រៅក្រោម ទឹងជនដែលប្រទូក ប្រទុស្តប្រមាទដល់ប្រាណ ។ តាំងមិនទុច្ចរិត ទៅរកមិត្តលាបសន្តាន ឬជនជាតិក្រៀនលាន នេះជាគុណប្រសើរក្រៃ ។»

៣០ ថៃជាត្រៃថ្ម ?

(សុភាសិត)

«ថ្ងៃជាត្រៃថ្ងៃ ពាក្យនេះជាន័យ បំភ្លឺឲ្យយល់ អ្នកមានក្នុងលោក
ជាត្រសោកល កុំគិតខ្វាយខ្វល់ រកត្រូវផ្សែងជាតិ ។ ផ្ទះជាត្រផ្ទះ ជាទី
មានមាន: ធ្វើជាយសង្ហាត ធ្វើផ្ទះប្រែនជង ផ្ទះប្រាប់បងបាជ ធ្វើផ្ទះ
ក្រោយស្អាត សមល្អជាទីមុន ។»

២៧ - អ្នកណាក្នុងលោកនេះ ទំនេបធម៌ពិត លុះបះបង់អាយុ
សង្ខារទៅកើតក្នុងលោកខាងមុខ ក៏នៅតែនេបធម៌ពិត, អ្នកណាក្នុងលោក
នេះ ទំនេតែរបស់ឥតប្រយោជន៍ លុះស្លាប់ទៅកើតក្នុងលោកខាងមុខ
ក៏នៅតែនេបរបស់ឥតប្រយោជន៍ដដែល ។

(វិចស្យូត ក្រេក)

« ទុច្ចរិតសុចរិត ដែលជនប្រព្រឹត្ត ក្នុងជាតិនេះណា គាបជា
ទំស្រ័យ បច្ច័យភ្ជាប់ ដិតជាប់គ្នា ទៅបរលោកខាង ។»

២៨ - ធម៌បរិសុទ្ធបានបង្កើតជាតុ ហើយគាត់តែងឲ្យមានបែប
ភាពជាខ្លួនប្រាណ នៅជាប់ចាំងរស្មីនៃធម៌បរិសុទ្ធនោះមតជង ។

ដឹនីស ( អារេអ្វប៉ាស៊ីត)

«សរីរៈនៃសត្វសត្វ ទីធម៌ចាក់ផ្ដុំជាតុបួន លាយផ្សំគាមសំខួន កើត
ជាខ្លួនថៃតា ។ ណា ៗ ក្នុងខ្លួនសត្វទាំងឡាយ មានបំពាយនៃបញ្ញា ស្មើ
ធម៌នាគ បេះដូងធម៌ក្រាក់ ។»

២៩ - ស្លាប់គឺរស់, រស់គឺស្លាប់ ។

(វិបស្សនាកម្មដ្ឋានក្រែក)

«ស្លាប់ទុកដូចជារស់ បានចំពោះផលជនណា កាលរស់ទំធ្វើការ ជាប្រយោជន៍លោកទាំងពីរ ។ រស់ទុកដូចជាស្លាប់ គឺជនកាចអន់ថោក ក្តី មិនធ្វើប្រយោជន៍ពីរ ដ៏ជាទីគោរពឡើយ ។»

៣០ - ពន្លឺសួគ៌ ប្រាជ្ញធ្ងុះ ។

ហេរាក្លីត

«អ្នកមានពន្លឺប្រាជ្ញា  នៃសួគ៌ចន្ទាពាធពិសេស
ផ្គង់ចិត្តព្រមធ្នាវិសេស  ស្ទួយជាតិប្រទេសឲ្យពិសាល ។
អវិជ្ជានឹងឥតជិតស្រស់កាន់  មានតែព្រះច័ន្ទញាណត្រកាល
អាចបម្រុងធ្ងុះភ្លឺខ្ចាលព្រាល ហើយបណ្តាលឲ្យយល់ស្គាល់ហេតុផល ។»

៣១ - ដើម្បីនឹងឲ្យរូបផែលសង្ខារគោកតែងតាមលំនាំកុសលា-កុសលចិត្តកើតឡើងបាន ដោយអាស្រ័យធម៌ ៣ យ៉ាងគឺ ទុក្ខ នាម ធាតុ ។

អារិស្តូត

«ទុក្ខសច្ច, នាមរូប, ធាតុបួន ជាធម៌ប្រជុំជួយសង្ខារ
កាត់តែងរូបអង្គតាមកុសលា - កុសលចិត្តសានុទូបទ ។»

៣២ - ធម្មជាតិដែលកាត់តែងធាតុជាដំបូង គឺបរមាណូ និង អាកាស ។

ដេម៉ូគ្រីត

«បរមាណូទីអាកាស មិនអាចវិនាសសូន្យបាត់បង់
តែងកើតជាធាតុពពុះ ដែលគួរប្រាជ្ញខ្នង់ហៅអវិជ្ជា ។»

៣៣ - មនុស្សសប្បុរសទៀតទេ ព្រោះយល់ឃើញថាការឲ្យជាអំពើល្អ ។

អារិស្តូត

«ការឲ្យទានដោយមានក្ដីសន្ដោស ប្រណីប្រោសអ្នកក្រីក្រគ្មានរស់
តាំងជាកិច្ចលះកំណាញ់ចេញឲ្យអស់ ទើបសប្បុរសថាការឲ្យជាកិច្ចថ្លៃ ។»

៣៤ - បុណ្យកុសលនាំឲ្យកើតសម្បត្តិគ្រប់យ៉ាង ។

ញ៉ាគុះ

«បុណ្យកុសលឲ្យកើតផលតាមនិស្ស័យ តាមបំណងអ្នកបានសាងពីអតីត
តែប្រាជ្ញគុណជាបណ្ឌិតទុំប៉ុនពិត បានលំទំនាំឲ្យកើតសម្បត្តិគ្រប់ ។
ដែលថានោះក៏មិនខុសពិតជាត្រូវ តាមដោយផ្លូវសុភាសិតព្រះបរមគត
សព្វធម្មទោឲ្យផលសព្វ គោលបញ្ចប់ថាឲ្យផលតាមប្រាថ្នា ។»

៣៥ - សារ៉ុះគោរពចំពោះព្រះ ត្រូវស្គាល់ព្រះអង្គ ហើយនឹងប្រព្រឹត្តតាមព្រះអង្គ ។

ពិថាកូ

«ខ្ញុំគោរពចំពោះព្រះ
ដោយមានចិត្តចង់ច្បាស់ស្គាល់ព្រះអង្គ
ដែលមានគុណវិសេសខ្ពង់លើសពួកសត្វ
ហើយតែងប្រឹងស្មោះត្រង់ប្រព្រឹត្តតាម ។»

ប្រព្រឹត្តដើរតាមដំណើរគុណ តាំងនោះ
ឲ្យមានឆ្ពោះក្នុងចិត្តស្មោះជាប់ជិតជាម
ជានិស្ស័យលះអាល័យគន្ធកាម
ដែលពួតផ្ទាយជាដើមតាមបៀតបៀនកាយ ។»

៣៦ - កម្លាំងឈើជាគុណសម្បត្តិសត្វតិរច្ឆាន , កិរិយាសុចរិតជាគុណសម្បត្តិមនុស្ស ។

ពិថាគ្ករ

«កម្លាំងជាគុណសត្វតិរច្ឆាន   ធម៌លក្ខណជាគុណពួកមនុស្ស
កម្លាំងជាគុណអសប្បុរស   ឧបាយជារបស់ពួកបណ្ឌិត ។»

៣៧ - ត្រូវបរិភោគអាហារដើម្បីឲ្យជីវិតរស់នៅ ហើយមិនមែនរស់នៅដោយគ្រាន់តែចាំបរិភោគទេ ។

សូក្រាត

«បរិភោគអាហារព្រោះថារស់   ជីវិតស្រស់បស់បានសុខសាន្ត
តែត្រូវបរិភោគជួនប្រមាណ   ទើបជីវិតប្រាណអាយុវែង ។
រស់ហើយត្រូវឲ្យប្រកបការ   ដែលមានខ្លឹមសារដល់ខ្លួនឯង
យ៉ាងនេះទើបពេញជាប្រុសវែង   កិត្តិគុណជាប់ស្តែងវែងមិនបាត់ ។»

៣៨ - មើលទៅរូបរាងឃើញសំណាក់សំខ្លួនស្អាតបាត តែខួរក្បាលគ្មាន ។

ហ្វេដ្រឺ

«រូបកាន់ពិសី ខ្ញុំកន្ទិសិរសី ការក្រក់មហិមា ប្រព្រឹត្តខុសពីគេ តាំងតែព្រាថ្ងៃ ទេសជាតិសាស្នា ក៏គ្មានជួយស្រួយ ។ ជនចុះនេះណា ខុសជាបន្ទា ដែលមុតល្មួយ ផ្ទុំជាតិឲ្យថោក កន្លែលោកយមួយ បណ្តែត កែងព្រួយ ទាបមនុស្សពាលនេះ ។»

៣៩ – ស៊ី! តែកន្លែលោកនេះ មានតែសេចក្តីសាបសូន្យហ៎! ។

ហ្វៃដិ

«អទិដ្ឋំ ទុក្ខំ អនត្តា ធម៌ ៣ នេះជាព្រះត្រៃលក្ខណ៍
ដោយអត្តាត្រូវកំណត់ជាក់ មានគ្រប់សត្វក្នុងត្រៃភព ។»

៤០ – បើចង់បានសាច់ពីក្នុងផ្ទុំបក់ ត្រូវតែបំបែកផ្ទុំបក់ តាំងមូល ។

បុត្រ

«ពជសីហាប្រាថ្នាពស្តុចំណី ដេកស្ងៀមនៅជីហាមាត់ចាំ
ឲ្យម្រឹគដើរចូលមាត់ទើបញាំ យ៉ាំងនេះកប់ឆ្នាំក៏គ្មានដី ។
អ្នកទៀនអ្នករកទ្រព្យសម្បត្តិ បើមិនលះបង់ការកប្រឹងប្រែង
ខ្ជិលទៀនខ្ជិលរកដូចពជសីហា រីដ្ឋាទ្រព្យឥតបំពេញចូលទេ ។

៤១ – ការមិនមានកេរ្តិ៍ ល្អទី ១, រូបល្អគង្គាក ល្អទី ២, មាន ទ្រព្យសម្បត្តិ ល្អទី ៣ ។

ហ្វ៉ាគុង

«ការគ្មានចេតលោភទុកជាល្អមួយ
ព្រោះជាគ្រឿងជួយឲ្យកើតសម្បត្តិទ្រព្យ
ភាពរូបស្អាតបាតស្រស់បស់សមគួរគាប់
ជាផលកំពូលជាប់កើតមានដោយគ្មានពេក ។
ទុកជាថ្លាក់ផ្ដាច់ជាល់គពីរ
ឯភោគីសម្បត្តិមានគេគោក
លោភទុកដាក់ថ្នាក់ទីបីលែងមិនស្អាត
ព្រោះជនភោគជាតនេះឯងព្រោះមិនឈឺ ។»

៦៦ - ត្រូវយកទ្រព្យដែលដូចគ្នានឹងធម្មជាតិ មកនៃទៀបសៀយ ។

ហិពូក្រាត

«ត្រូវនៅក្ដៅត្រូវនឹងស្ទើរក្ដៅ បើកើតជំងឺមកកាយា
កកម្ពុលទល់ចុងឈើនេត្រា បញ្ចុះកាហាហោសហោលសិន ។
ឲ្យជាគុក្កន៍ខ្ទួនបែប្រែជាក់ រូបហើយសឹមដាក់ថ្នាំសង្កិន
ពេលនោះវិនាសពាកកាយឥន្ទ្រិយ៍ ដោយសារពេទ្យពុំពិនិត្យពេក ។»

៦៧ ពិតមែនតែនគរក្រិច ទៅជាមហាព្យាក្រិត, នគរអ៊ីតាលី ក៏មិនព្រមទទួលឥទ្ធិព្រោះ ដោយសុចរិតស្មោះត្រង់ចំពោះនគរនេះ ហើយយកអំណាចមកមោះគ្រឹះដែលនៅចំណុះនគរយើង ។

ខ្ញុំបានតបទៅកាន់រដ្ឋមន្ត្រីអ៊ីតាលីថា ខ្ញុំយល់ឃើញថា លើទឹក បញ្ហានេះនិងភាពកិរិយាដែលតាមតាមទឹកដីនេះ ទុកដូចជាសេចក្តីប្រកាសសង្គ្រាម, តែនៅពេលនេះ យើងនៅតែទទួលបង្ហាញឲ្យឃើញជាក់ស្តែង នូវទឹកចិត្តក្លាហាននៃជនជាតិរបស់យើង ដែលលះបង់អាយុជីវិត ដើម្បីការពារសន្តិភាព និងប្រទេសជាតិយើង ។

សុន្ទរថា លោកមេតាក់សាស

នាយករដ្ឋមន្ត្រីហេលែន ថ្ងៃ ២៩ . ១០ . ៤០ ។

៤៤ - ត្រូវយើងប្រមូលចិត្តមួយគំនិតគ្នា ធ្វើសេចក្តីសាមគ្គីឲ្យច្បាស់កុំសង្ការទៀត ត្រូវយើងចូលទៅតយុទ្ធនឹងបច្ចាមិត្រ ដើម្បីទុកកិត្តិយសនិងឥស្សរភាពប្រទេសយើង ។ កិច្ចដែលយើងត្រូវបំពេញគឺការពារប្រទេសជាតិ ទាល់តែអស់ជីវិតរៀងខ្លួន ។

ព្រះរាជឱង្ការព្រះបាទស្សូរស៍ប្រទេសក្រេស (២១ . ៤ . ៤១)។

អាចារ្យឌិញ - ប្រាជ្ញ

(តទៅ)

---

## គ្រឿងដឹក

គាវី ៗ នេះគេយកឈើឬឫស្សី ប្រវែងជាង ៤ ម៉ែត្រឲ្យមានខ្នង ទៀនចង្កូបធ្វើជាមេពីរដាក់សងខាង ហើយរំលងកោលពីខាងគល់មេនោះ ចំនួន ១ ហត្ថជាប់ត្រណាប់ ១ គពីត្រណាប់មុខនោះ ៦ តឹក ត្រណាប់មួយ ៗ រួមទាំងអស់ត្រណាប់ ៣ ត្រណាប់នោះធុំឲ្យគូបធំពេកឲ្យតែជួនល្មមខ្នង មេនោះ ហើយយកឈើឫស្សីណាដែលក្រាស់ ៗ ប្រវែង ៧ តឹកមកចាក់ ជាពីរលាក់ពាក់កណ្ដាលធ្វើឲ្យគូបលើឲ្យក្រោមធំជាងបន្តិច យកមកស៊ក ខ្នងត្រណាប់ដែលជាប់ខ្នងមេនោះ មេ ១ សសរពីរ ៗ ហើយយកឈើ ១ ចម្រាស់ប្រហែល ៤ ហ៊ុន បន្ទាប់ខ្នង ១ តឹក បណ្ដោយឲ្យវែងជាងត្រណាប់ ទាំងពីរនោះបន្តិច ហើយដាប់ត្រណាប់ឲ្យត្រូវខ្នងសសរទាំងពីរនោះឲ្យ ធ្លាយទៅម្ខាង ហើយយកមកស៊កខ្នងសសរដែលយើងដោតលើមេ ឲ្យត្រឹមដែលលាក់នោះហើយយកឈើ ១ ទទ្រើងទៀតប៉ុនដដែលដាប់ចុង ដើមឲ្យធ្លាយ ហើយស៊កខ្នងសសរ មេទាំងសងខាងធ្វើជាសន្ទះមុខ ក្រោយហើយដាក់ខ្នង ២-៣ វែងរនាបឲ្យរង្គើលបន្តិចល្មមតែក្រលស៊ក

ចុកខ្ទល់កុំឱ្យធ្លាយស្រូវទៅក្រោមបាន គារនេះមានទ្រង់ទ្រាយបួនជ្រុង
ទៅនឹងដូចត្រយ៉ងជើងជម្ពាននោះឯង តែកែមានរនាំងពីក្រោមសម្រាប់
ឱ្យគោក្របីស៊ីបានប៉ុណ្ណោះ ។

## សាឡី

សាឡីនេះមានមេដូចគារដែរ តែកែមេនោះមិនជាប់មេគារបន្តិច
ហើយមានកង់មានធ្មេញនៅជុំវិញដូចរនេះ តែកង់នោះគេយកក្តារក្រាស់
ចំនួន ៨ បន្ទះ ទំហំប្រមាណ ៨ តឹក ក្រចៀងឱ្យមូលជាប់គ្រណាប់ ឱ្យធំ
កណ្តាល ហើយយកឈើមួយមូលចំនួន ២ ហត្ថ ចាំងឈូសឱ្យមូលជ្រុ
ជាភ្លៅ ហើយយកឈើ ១ ទៀតក្រាស់ជាង ១ តឹកបណ្តោយប្រហែល
ជាកន្លះម៉ែត្រ យកមកដៃកកោតឱ្យមូលជ្រៅល្មមតែបង្កាន់ផ្នែងភ្លៅចុះបាន
មិនបង្អៀត ហើយយកមកចងពីខាងក្រោមមេឱ្យជាប់ ឈើនេះហៅ
ត្រពងសាឡី ពេលដឹកស្រូវយកកង់ដែលបោះជាប់នឹងភ្លៅហើយនោះមក
បង្កាំពីខាងក្រោមត្រពាំងនោះទៀត សាលីនេះគេធ្វើឱ្យមានប
មួយ ពេលដឹកផ្លូវទៅមុខមិនស្រួល សាឡីនេះដឹកបានតែងស្រូវ
គ្រាប់ស្រូវគណ្តាប់ តែដឹកបានតែស្រូវណាដែលគេគរ ឬស្រូវ
ទៅកក់ ឬមានទឹក ដឹកមិនបានទេជាប់កង់ ។

## ដំជៀវ

ដំជៀវនេះ គេយកឈើប្រហែលប៉ុនកំភួនជើងប្រវែងជាពីរហត្ថ ហើយកោងកណ្ដាល ត្រូវដាក់ទៅនឹងកក្របីគោឲ្យត្រង់ខ្នងល្អហើយ លាក់ក្បាលសងខាងឲ្យមានជាសន្ទាត់ប្រយោជន៍ចងខ្សែកុំឲ្យរអិលរបូត ពេលដឹកយកទៅបំពាក់លើកក្របី ឬគោ ហើយមានខ្សែ ១ ចងព័ទ្ធពីក្រោមកក្របីគោ ហៅថាខ្សែទាម ហើយមានខ្សែពីរទៀត ដែលចងចុងមេគាវ ឬមេសាឡីទាំងសងខាង ហើយយកចងភ្ជាប់នឹងសន្ទាក់ក្បាលដំជៀវទាំងសងខាងហៅថាត្រចៀកគាវ ឬត្រចៀកសាឡី ។

## ប្រដាប់សំរាប់បោកស្រូវ

### ការបោក

ការបោកនេះបណ្ដោយប្រវែង ១ ម៉ែត្រ ទទឹងចំនួន ៤-៥ តឹកក៏បានកម្រាស់ប្រហែលជា ៥ ហ៊ុន ចុងម្ខាងជាប់ត្រណាប់ពីរ ដាក់ជើងឲ្យខ្ពស់ឡើងចំនួន ៥ តឹក ចុងម្ខាងសំយុងចុះដល់ទៅនឹងដីពេលបោកស្រូវគ្រាប់ស្រូវហូរទៅឯងមិនបាច់ចាំកាយ ។

### តំបៀត

តំបៀតនេះគឺឈើសំរាប់ត្បៀតកណ្ដាប់ស្រូវបោកធ្វើបានពីរ ១ វែង ១ ខ្លី ១ វែងប្រវែង ៤ តឹកកន្លះ ១ ខ្លីប្រវែង ៣ តឹក ១ ខ្លីលាក់ផល

ទៅចុងឲ្យមានស្នាមបន្តិច បងខ្សែកុំឲ្យរបូត ១ ខ្សែណាក់ពោលពីចុងមេ ប្រវែង ១ តឹកកន្លះ ហើយយកខ្សែវេញភ្ជាប់ឈើទាំងពីរត្រង់លាក់នោះ ចំនួន ១ ចំអាមពីគ្នាឲ្យជាប់ ខ្សែនេះយកចំណាំងស្អំវេញក៏បានដែរ ដោយ ហោចទៅតែណាំងចេកស្ងួត ឬចំបើងក៏បានដែរ ឲ្យតែជាប់ ហើយយក ទៅគៀតស្រូវដែលច្រូតបង់ជាបាច់ហើយនេះបោក ៗ .

## ព្យែរ

ព្យែរនេះ គឺជាប្រដាប់សម្រាប់បោកស្រូវម្យ៉ាងដែរ ប៉ុន្តែគេមិន បានដឹងមកដល់ណាន ហើយបានបោចដូចបោកក្តារនោះទេ គឺគេយក ក្រលៀមទៅកាត់ត្បូងស្រូវឲ្យបៀតទៅតល់បន្តិច មិនបាច់បងជាកណ្តាប់ទេ តាក់តាដាក់ ១ ដុំៗ ហើយយកដំបៀតទៅគៀតយកមកគ្រាប់ព្យែរតែម្តង ព្យែរនេះមានរូបរាងដូចនេះ គឺគេយកក្តារចម្រាស់ចំនួន ៣ ហ៊ុន បន្ទាប់ចំនួន ២ តឹក យកមកធ្វើជាមេពីរសងខាង ហើយដាប់មេទាំងពីរពោលពីខាងចុង ចំនួន ២ តឹកម្ខាង ដាក់មេទទឹងចំនួន ៨ តឹក ហើយដាក់រនូត ២ - ៣ ក្រាលក្តារឲ្យជិតកុំឲ្យលេចគ្រាប់ស្រូវបាន ពងព្យែរនេះ ដូចកូនត្រែ យើង អង្គុយលេងជម្ពាតនោះ ប៉ុន្តែធ្វើមានផ្ចាំងខ្ពស់ទៀងលើទៀត គឺមាន ដាច់ក្រណាប់តូចៗជុំវិញ មេព្យែរនោះចំនួន ១ តឹកៗពីគ្នា ហើយយក បន្ទះឬស្សីចុំពីរជាប់ប្រវែងពីរម៉ែត្រ យកមកដោតតាមក្រណាប់នោះធ្វើ ជាចំរឹងបញ្ជរ ៣ ជ្រុងគឺសងខាងនិងខាងក្រោយ ហើយអបរណបតាំង

ពីក្រោមរហូតដល់លើ ប៉ុន្តែឲ្យមាត់លើរីកធំបន្តិច ហើយអាចស៊ុកពីខាងក្នុងរហូតដល់លើម្តងទៀត ខាងមុខដាក់ចំរឹងកំពស់ប្រហែល ៥ តឹកបុន ហើយៗមានទំហំបន្តិចមាត់លើបំពង់ប៉ុនកក្តួនដៃផង ហើយបាំងស៊ុករៀងជិតដូចគ្នាដែរ ហើយយកឈើឬឫស្សីធ្វើដូចជាជាន់ដើមទទឹងឲ្យប៉ុនមាត់បោះបណ្តោយប្រវែង ៧ តឹក ដាក់កាំឲ្យញឹកចំនួន ៦ ឆ្នាប់មួយៗយកមកដាក់កល់លើមាត់បោះសម្រាប់ធ្វើជាកំណល់បោះ ។

## រនាស់ដៃ

រនាស់នេះ យកឈើវង់ ៤ ហ៊ុន ៤ ជ្រុង បណ្តោយប្រវែង ៥ តឹកដាក់ធ្មេញឲ្យញឹកបន្តិច ព្រោះរនាស់នេះសម្រាប់ខ្ទាស់ស្មៅទន់ស្ពង ស្រែដែលបោកដាក់ប្រមូលយកទៅដាក់ ១ អន្លើ ហើយបែនដោយជើង ឬដោះ ហើយភ្ជួរយកបានឲ្យតែគ្រាប់ស្រូវបានច្រើនល្អ ដងយកកូនឫស្សីឬក៏ឈើតង់គូបល្មមប្រវែង ១ ម៉ែត្រកន្លះ ឬពីរម៉ែត្រប៉ុណ្ណោះ ។

ប្រដាប់សម្រាប់ធ្វើស្រែតាំងក្នុងរដូវភ្ជួរនឹងរដូវរាស់ហើយ បានរៀបរាប់ដោយសព្វគ្រប់អស់សេចក្តីតែប៉ុណ្ណេះ តទៅនេះនឹងរៀបរាប់អំពីរបៀបធ្វើស្រែដោយបច្ចេកទេស ។ ការធ្វើស្រែបែបត្រៀម (ថ្នាល) សាបសំណាបជាមុន ។

# អំពីការធ្វើទី

ទីសម្រាប់សាបសំណាបនាទតំរៀប   គឺទីគ្មានដីខ្សាច់ ៤ ទីមានដី ខ្សាច់ ១ ទីនេះតែក្បៀនថ្នាំមគមានទឹកល្អ ៗ គេត្រូវហើយយកសំឡេង ដែកសព្វទាំងអស់ ហើយប្រមូលរើសដើមស្មៅទំនងលើកព្រាំងយះទៅ ដាក់តាមភ្លឺទីនោះទាល់អស់ ហើយយកសំដែមឲ្យដីម៉ដ្ឋល្អមែនទែន បើដី ម៉ដ្ឋល្អហើយត្រូវធ្វើរនាស់ពីការងារខ្ទីបរកែខឲ្យដើកបល្អម្ពរទៀត បើទីគ្មាន ដីខ្សាច់ តែកែខឿងរនាស់រួចហើយ គេធ្វើបន្ទូរតើរតាតទទឹងទីពីក្ដោងម្ខាង ទៅក្ដោងម្ខាងទៅបានតិចជាតតំរុយ ១ គឺយកមែកឈើឬបន្ទះឬស្សីក៏បាន ដែរ បើទីនោះធំត្រូវធ្វើរបន្ទូរឲ្យច្រើនហើយ ដើរពីបន្ទូរ ១ ទៅបន្ទូរនោះ យើងស្មានមើលប្រហែលជាបាចត្រាច់ស្រូវទៅដល់ប្រសព្វគ្នា បើតាម ដែលបានធ្វើមកនោះ ពោលវត់ង ៤ ម៉ែត្រពីគ្នា ដែលត្រូវឲ្យដាក់ តំរុយនោះព្រោះទីនោះធំ បើយើងមិនដាក់តំរុយទេ យើងមិនអាច ដឹងបានថា ត្រង់ណាបន្ទូរ ត្រង់ណាមិនមែនបន្ទូរ ព្រោះមើលមិន ឃើញស្នាមជើងដែលយើងដើរទៅនោះ ម្យ៉ាងហើយដល់ពេលសាបមិន ដឹងថាសាបបានដល់ត្រឹមណាជាត្រឹមណា អាចប្រឡំទៅសាបលើកន្លែង ដែលសាបហើយក៏សឹងមាន បើយើងបានដាក់តំរុយជាស្រៀងសំគាល់ យើងដើរតាមតំរុយបន្ទូរនោះទៅ ងាយដល់ការសាបផង ហើយមិន ភាន់ច្រឡំកន្លែងដែលសាបហើយ ឬមិនទាន់សាបផង ។ ទីដែលមានដី

ខ្សាច់ក៏មានការក្តៅកេសរ៉េស ស្មៅក៏ខ្ទីរនាស់ដូចដីគ្មានដីខ្សាច់ដែរ ឬក តែដីមានដីខ្សាច់ត្រូវបាចជីឲ្យច្រើន បើដីនោះមានដីខ្ពស់ទាបមានទឹកដក់ នៅខ្ទះត្រូវលើកប្រឡាយឲ្យហូរមកកន្លែងណា ១ ហើយបាចបញ្ចេញឲ្យអស់ ទីមានដីខ្សាច់ បើមិនបាចទឹកចេញឲ្យអស់ សាបមិនដុះស្រែដែរ សាប នៅនោះទៀតនឹងពុកអស់ ហេតុហ្នឹងត្រូវបាចទឹកចេញឲ្យរីងទើបសាបបាន ទីនេះល្អាយសាបទេ ព្រោះបាចទឹករីងមើលឃើញបង្អួរ ដែលយើងដើរ ហក់ចំទីទំ ទុកជាដូច្នោះគឺត្រូវធ្វើបង្អួរដែរ ព្រោះដល់ពេលសាបយើង ដើរតាមបង្អួរនោះសាប ។

## អំពីស្រូវពូជ

ស្រូវពូជនោះត្រូវសំកាំងឲ្យល្អ គឺរើសស្រូវណាដែលពេញៗគ្រាប់ កុំឲ្យមានស្កូកស្គី កុំឲ្យលាយដោយមុខស្រូវដទៃ តែមានលាយដោយ មុខដទៃ ដល់ពេលចុំៗ មិនស្មើគ្នា ជាហេតុលំបាកដល់ការប្រមូលកាត់ មានមុនក្រោយ ស្រូវដែលត្រូវការយកមកធ្វើជាពូជនោះ មានច្រើនមុខ ណាស់មានធ្ងន់មានស្រាលផ្សេងៗគ្នា ហេតុហ្នឹងត្រូវជ្រើសរើសមើលឲ្យ ដឹងថាស្រូវណាដែលមានផលល្អយើងត្រូវយកស្រូវនោះមកធ្វើជាពូជ ។

ម្យ៉ាងទៀត ត្រូវពិនិត្យមើលដល់ក្តូមស្រូវផង តើក្តូមស្រូវនោះ មានដំណុលខ្ពស់ច្រើន ឬច្រើនទៅដោយចង្កូមក្រពាំង បើស្រូវនោះ មានដំណុលខ្ពស់ច្រើនមានទឹកតិច ត្រូវដាក់ពូជស្រូវស្រាល ព្រោះស្រូវ

នោះអាចទុកទាន់ពេលវេលាដែលទឹកនៅមានខ្វះបន្តិចបន្តួច បើសិនណាដាក់ពូជស្រូវធ្ងន់ស្រូវនោះក្រទុំ ទឹករីងស្ងួតអស់ទៅជាហេតុនាំឲ្យស្រូវនោះស្កកខ្ចូបអស់ បើស្រែនោះច្រើននៅដោយបំនប្រែកពាំងមានទឹកច្រើន ត្រូវដាក់ពូជស្រូវធ្ងន់ព្រោះស្រូវនោះក្រទុំ ទំរាំតែទុំទឹកក៏ស្រកទៅអស់ច្រើន បើទឹកស្រកច្រើនហើយស្រូវដែលទុំនោះមិនលិចល្អយទៅក្នុងទឹកផង ហើយងាយដល់ការច្រូតកាត់ផង បើសិនណាដាក់ពូជស្រូវស្រាល ស្រូវនោះឆាប់ហើសទុំក្នុងពេលទឹកកំពុងច្រើន ស្រូវនោះក៏លិចលង់បង់ខាតទៅក្នុងទឹកផង ហើយលំបាកដល់ការច្រូតកាត់ផង ហេតុហ្នឹង មុននឹងយកស្រូវមួយៈធ្វើជាពូជត្រូវពិនិត្យទីពិនិត្យដល់ភូមិស្រែឲ្យហ្មត់ចត់ជាមុនសិន ទើបបានមិនបង់ខាតហើយងាយធ្វើផង បើដាច់ស្រេចថាយកស្រូវណាមកធ្វើជាពូជត្រូវរៀបចំត្រាំ ។

## អំពីការត្រាំពូជ

ត្រូវយកស្រូវទៅដាក់ក្នុងរបស់អ្វីដែលអាចដាក់ទឹកបាន ដូចជាពាងជាដើម ហើយដងទឹកឲ្យលិចតែលិចគ្រាប់ស្រូវត្រាំទុកចំនួនពីរយប់ ហើយស្រង់ឡើងយកទៅដាក់ក្នុងកញ្ជើ ឬកញ្ចើ . ឬរបស់អ្វីដែលអាចស្រកទឹកបាន ហើយយកកន្ទេល ឬស្លឹកគ្របឲ្យជិតធ្វើឲ្យហប់ដើម្បីឲ្យគ្រាប់ស្រូវដុះល្អ ការជ្រាប់ស្រូវទុកនេះខ្លះជ្រាប់ទុក ១ យប់ ខ្លះជ្រាប់ទុក ២ យប់ ដើម្បីឲ្យគ្រាប់ស្រូវដុះពន្លកបានតែបន្តិច ។ (មានត)

# រឿងភោគកុលកុមារ

## អ្នកឧកញ៉ាព្រះឃ្លាំង ឥង

(តមក)

អ្នកខ្ញុំបណ្ដែត ដោយខ្សែកំណើត ៤ខែចំហាត្រា ស្រែកស្រែះតែពន់ ទន់ៗ សុរិយា ផល់នូវផលសា សមុទ្រជោរជល ៗ ចំហាំ ១០ យោជន៍ លន្លឹមលនោច ប៉ាំងត្រើយពុំឃើញ ទើបអ្នកឈប់ខាន សម្រាន្តកាយ-ពល នៅតាមណ្ដាល មួយព្រឹកព្រាសាយ ៗ អ្នកគិតថាថា ហៃសុខា សស្ដុតពណ្ណពយ សមុទ្រនេះធំ ទំហំសាគឡាយ មើលទៅតំណាយ ផុតត្រើយពុំឃើញ ៗ ហេ៍នទំនងហែលខ្លួន ប្រាំងរួចរស់ពីកន្លែងផល-សាសមហើនក្សៀង ប្រាំយស្ងួនស្លល់ ពិតពុំបានផល់ គ្រែរត្រាណ ជួបប់ន ៗ នប្អូនពលព្រាណ ម៉្រះសមពុំបាន ផល់ជួបចំណាន សម ទំនឹហ្វាតហ្វា កាលត្រានេះមួន ខ្សែតទំនងហែលខ្លួន ទំកទៅពុំបាន ៗ នប្អូនព្រលឹង ម៉្រះសមទទួន កដិចិត្តគិតស្មាន ចាំបន្តាមទៅ ផល់ ពៅពលព្រាណ មិនដឹងជាខាន នៅនូវផលសា ៗ សុខនឹងស្លាប់ហើយ ជាអង្គាស់អើយ កុំព្រួយបន្ទា កាលនានឹងទៅ ផ្ដាំទូវខ្ញុំថា សមុទ្រ ជលសា នេះពក់ពុំត្រជាក់ ៗ លេមដើរខ្លួនបាន ហែលខ្លះដោយដាន អន្ធ ដំរៅ យប់នេះស្លាប់ខាន សម្រាន្តទត្យអៅ ព្រឹកឡើងខ្លួនទៅ ខ្ស ផល់ត្រើយត្រាណ ៗ កោចសត្វស្លាប់ សុខស្រាយស្រាប់ អ្នកជិត

ដោយដាន ពាក្យពីតានភ្ញាំ ថែទាំមិញខាន ឬទ័យស្រាកស្រាន្ត ស្រស់
ស្រាលខ្លា ។ អ្នកក្លួយបំពោះ ព្រែងឡើងចរចុះ ទៅក្នុងផលសា
ដើរខ្វះហែលខ្វះ រុតរះយាត្រា ឯសុខា ហែលតាមទៅផង ។ ក្នុង
ផលសាគរ មច្ឆាតែរ ត្រាស់ត្រែកខ្ទង់ លៀសងាំរែត្រីងត្រំ ភិរម្យ
ទៅឡើង បង្កាបង្កង ចំចៀបចាក់ប្រែង ។ មានត្រីក្លាំងហាយ ក្លាំង
ហាតខ្ទាយ ក្ទរកណ្ដាន់ កណ្ដាកផ្ចង់ ពេនរែងផងខ្វង់ ឆ្កោក
ក្លាប្រៃផង ផ្កាតាសេណ្ដាយ ។ ត្រហែត្រះហា ត្រីមាល់ទំពោ ត្រីម
ក្រាញ់ក្រសក្រាយ ត្រទងត្រសក់ កាចម័ក្លុតក្រឹមសាយ ឆ្កោសំពារ
ប្លាយ អំពិលទុំទុំ ។ ព្រលូងប្លាអៀរ រៃត្រងត្រំភ្លៀរ តំក្រាញ
កំភ្លុក អន្ទង់ប្រាត់ប្រា ឆ្ដោរផ្ដៅងផ្ដុក គីគក្តរែកញ្ចុក សោតប៉ុចបង្កា ។
ចក្រះចញ្ចាក់-ស្លាស្លាតត្រីប្រាក់ ត្រីពលត្រីខ្លា ឆោសប្លាតូ ប្លាម៉ូចាមាំ
តល់កំផ្លកផក-ហ៊ូហែលរៀបរៃប ។ កញ្ចុកកញ្ចាញ-ប្រាសប្រលឹង
លេញ កន្ត្រប់ផងដៃ ចក្សលេកសរៃ ស្លូងមែម៉ារ កណ្ដេតត្រៃស
ត្រសងហិចហែល ។ ក្រពាត់ក្រពត ត្រពើច្ចកប្រក ខ្លាមក្ទាំង
ចបែល ត្បូតត្បូតរៃខ្ទុកគ្នា សៃត្រាទៃនល កំកេកេកល ពិន្ទុងម្ក ។
មុជហែលលើលា លលេញផញ្ញា ជជំកខ្លាយខ្ទរ រអែតរល់ ក្នុង
ផលសាគរ ក្រាស់ក្រៃកៃ អនេកអនេកា ។ ហេតុព្រះបារមី ពន្លក
ជិនស្រី សំពៅឆ្លងសាស្ត្រ អស់សមុទ្រសាគរ ចៀសចរញ្ជួន ពុំមាន

ហិនភ្ជា បៀតបៀនប្រមាថ ។ អ្នកទាំងហាលដួង ឲ្យរួចរលង ពីគុន
ផលផាត សុខទសសឹង ទំប្រឹងសង្វាត ហាលពុំឲ្យឃ្លាត ពីព្រះតោធី ។
អស់ឥតកំឡាំង វៀរពេយផេនតាំង ញ៉ាំអស់ឥន្រ្ទិយ ទំហលហាក់ហើយ
ផល់គ្រើយផលធី ក្សិណក្សយដីរ ប្រែប្រួលសាគរ ។ ពន្ធកខសពល
មៀនមើលយន់យល់ សុខទមិញមរណ៍ អ្នកសែនហោយហោន ទើប
យកព្រះករ ទាំងពីរគក់គរ ពកខ្ញុំថា ។ ខ្ញុំសុខទអើយ ឥឡូវម្ដេច
ឡើយ បាទគមរណា ក្សិណក្សយតានបរ ប្រែប្រួលផលសា ហាល
អគ្គអញកា ។ សារសោះសូន្យសល់ ។ អញសង្វាតមន យាត្រារុករក
តាមនានទិមិល ហើយហាក់ពិបាក តោកយាំតតាមតល់ វែងតែបាន
ផល់ យល់នានទារ ។ សង្ឃឹមតែបា កំដរជាគ្នា ដើរដោយខ្លួនទី
ឥឡូវបាក្សយ ប្រល័យដីរ ទើកម្ពៀរពើ បុកណាទៀនពាក់ ។
ឲ្យអញកណ្ដែន តណ្ដាថ្ម៉ាក់ឯង កណ្ដាលព្រៃស្ងាត់ សៀមស្ងប់ជ្រុំ
ខ្លួនតែមពេចក្ខុត មាននៃសព្វសត្វ កំដរជាគ្នា ។ ខ្ញុំបានចក្ដ
ណបីផ្កាលអញពិត ពុំវែលឃ្លាតឃ្លា ដល់មួយពគ្រើ តោះបយាត្រា
ទៅឡើចំការ បាតាមទៅផង ។ បានមានគំនិត ពុំឲ្យព្រួយចិត្ត ផេរ
កាយផល់ម្ដង ។ យប់ព្រួសនិទ្ទុង ចាំក្នុងរបង មិនឲ្យសត្វផង ចូលធី
ដំណាំ ។ តោះអញពុំទៅ ត្រេបដើរលេងទៅ ខ្លួនបាឲ្យចាំ មើលហាន
ត្រឹហា តេក្របែចាំ ឥឡូវគឺឥម្ចុ ឯងឲ្យឃ្លាតឃ្លា ។ អ្នកខ្ញុំសព្វគ្រប់

សោកសៅសែនថប់ ស្តាយសុខា . ខ្សឹកខ្សួលអួលអាក់ ម្ចេញម្នាក់ឯងថា
ទុក្ខទោមនស្ស ថ្លែងថ្មីនពុំបាន ។ ល្អះបុណ្យកត្តៅ អ្នកជួយទាន់ទ័ ផ្ទេរ
ផលសាសាគ្គ ខ្ញុំទៅទេ ក្រៀកក្សៀណ ឋានទមាសមាន រូបកង
សោកា ។ អង្វរបង់មន ភាមប្អូនពន្ធក ថ្លាស់ធ្វើផលសា រូបបាន
ដល់ត្រើយ ហើយសុខា បាត់បង់មរណា ប្រចាំផ្លេដល់ធី ។ ម៉្មេះ
សមបង់ទាន គង់ព្រៃពុំបាន យល់ប្អូនពិសី ជ្រិតកកនរណា នាំ
មាតាពី កាយឲ្យដល់ចំ កំបន់ប្អូនក្ញា ។ សមបង់វាន្ទែង គង់ព្រៃ
នរណ្ណន នណ្ណាលកញ្ញា ម្នាក់ឯងក្សៀណក្សៀយ ប្រល័យជន្មា គង់ព្រៃ
ព្រឹក្សា ស្ងួនសោះអសារ ។ បង់គិតទៅគ្រប់ គ្រប់ហើយរឹងថប់
ថប់ប្អូនប្រេតារ ថប់មួយជ្រិតសុខ ទុំមទុនសងក្រៃ កំពុងពេញពាល
ប្រាសព្រាត់ឃ្លាតឃ្លា ។ ថប់មួយកតអួង ណាឧងចាំជាក់ ជងជាន
មាតា នាំនាំផ្លូវទៅ ដល់ពៅពិន់ ឲ្យបានជួបជា គូគួរស្នេហ៍ស្និទ ។
ថប់មួយគិតស្តាយ សុខអង្គកាយ បាត់បង់ជីវិត រឹងជាតណ្ណាន ម្នាក់
ឯងពេកពិត ត្រូវរឹងគាណិត អនាថអនិច្ចា ។ ថប់មួយខ្ទមបង់ ដើរ
ត្រែបដោយជង ទិទ្ធអញ្ញា គិតគ្រែកងពុំដល់ មណ្ឌលប្អូនក្ញា គិតទៅ
រឹងជា ថប់ក្តាក់ពេតពន់ ។ ព្រះពោធិសត្វ ពិលាបពេកក្តាក់ ខ្ញុំទៅ
ប្អូនគន់ សង្រែនិងសង្រែ ហ្វូចយកិតគន់ ខ្សឹកខ្សួលអួលអន់ ក្រែពេក
ជនន ។

សម្តេចគត់ ថ្កូលទេស្នា ថាហៃភិក្ខុផង នេះគឺកម្មពៀរ
ពាំទៀរជាប់ជន់ ពុំដែលរំលង បៀតបៀនគ្នា ។ កើតកូនសង្សារ ដូច
នៅកណ្តាល សមុទ្រផលសា ពុំដែលបៀតបាន វិបាកធ្ងន់ សឹង
មានវេរ ព្រេងមកផ្តិតផ្តល់ ។ កៀណខ្សត់កៀណមាន កៀណចង់
កៀណបាន យសសក្តិសុខសល់ កៀណត្រាត់កៀណព្រាស និពសពុំបេល
សឹងជាទុក្ខទល់ ដូចព្រះធម៌ថា ។ ត្រូវគិតទុក្ខំ ត្រូវគិតអនិច្ចំ ត្រូវគិត
អនត្តា ព្រះត្រៃលក្ខណ៍ញាណ ប្រមានទុំជា អារម្មណ៍គានោ រំពឹង
សព្វថ្ងៃ ។ សង្សារពុំសុខ តែងតែមានទុក្ខ នោះទៀងពេកក្រៃ
កៀណរស់កៀណស្លាប់ ត្រឡប់វិលវៃ កៀណកិតកៀណភ័យ ពុំដែល
សុខសាន្ត ។ ត្រូវគិតព្រះធម៌ ការនាអស់ការថិ ចូលព្រះកម្មដ្ឋាន ខំទង
ទំឲ្យដល់ ត្រើយជួលទិញាន ទំនេរសមិទមាន ទោសទុក្ខភ័យមរណ៍ ។
ទីរជាតិផក ព្យាធិកេត កេ្រមក្បួនបវរ បានសួគ៌ទេព កាមាវចរ
ពុំស្មើនគរ និព្វានថ្លាថ្លៃ ។ គេជះសម្ភារ គោតកុលកុមារ ពន្យុត្ត-
ញាណញៀញ្ញ នក្រៅថ្កូល ដល់សួគ៌ហើយ ពិតតបាននៃត្រ-ត្រៃង្ស
សួគ៌ាមាយ ។ អស់ញាតិតា គោតកុលកុមារ ដែលស្លាប់ពីកាយ យោន
យកកំណើត ទៅកើតសួគ៌ាមាយ សឹងក្តៅក្រហាយ ទឹងនៅពុំស្រាក ។
ប្រែបើកទិព្វចក្ខុ មៀនមើលឃើញជាក់ ថាទៅគោតកុល-កុមារសោយ
សោធ ការមានទូពល នៅនាស្ថេរជល ជាទុក្ខសល់ខ្ទាក ។ (មានត)

# វិជ្ជារក្សាចិត្តក្នុងបច្ចុប្បន្ន

(សុមង្គលវិលាសិនី)

## ឃុនបណ្ណានុរក្ស ប៊ូ-ប៉ូ ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

---

ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ទេសនាពន្យល់មនុស្សសត្វទាំងទេវតា ឲ្យស្គាល់ប្រយោជន៍តាំង ៣ ប្រការ គឺ ប្រយោជន៍ក្នុងបច្ចុប្បន្ននេះ ១ ប្រយោជន៍ក្នុងលោកខាងមុខ ១ ប្រយោជន៍ព្រះនិព្វាន ១ ។ ព្រះពុទ្ធដីកាដែលទ្រង់ពន្យល់អំពីប្រយោជន៍ក្នុងបច្ចុប្បន្ននោះ មានសេចក្តីវែងឆ្ងាយទូលាយជាច្រើនថែបច្រើនយ៉ាងណាស់ ដូចទ្រង់ពន្យល់អំពីការសេពគប់មិត្តភក្ក ការដើរលេងយប់, ការមិនសំគាល់ខ្លួនប្រាណ, សេចក្តីខ្ជិលច្រអូស ប៉ុណ្ណោះជាដើមជាបាបនាំបណ្តាលឲ្យកើតទោសសឹងមានក្នុងសៀវភៅព្រះពុទ្ធសាសនាខ្មែរស្រាប់ហើយ ។ ក្នុងទីនេះសូមស្រង់យកព្រះពុទ្ធដីកាដែលទ្រង់ពន្យល់អំពីវិជ្ជាសម្រាប់រក្សាខ្លួនឲ្យបានសេចក្តីសុខចំរើនក្នុងបច្ចុប្បន្ន ៧ យ៉ាង ជាកិច្ចដែលមនុស្សគ្រប់រូបធ្វើតាមបាន គឺវិជ្ជាសម្រាប់គំពារ ៖

១ — សេចក្តីវៀងឬភ្លៀប

២ — សេចក្តីល្ងង់ខ្លៅ

៣ — សេចក្តីខ្ជិលច្រអូស

៤ – សេចក្ដីតូចចិត្ត

៥ – សេចក្ដីមិនសប្បាយចិត្ត

៦ – ចិត្តមិនធឹងធ្ងន់ មិនធ្ងន់ធ្ង

៧ – ចិត្តមិនតាំងនៅជាកណ្ដាល

១ – វិជ្ជាកំហាត់វង្វេង, ភ្លេច មាន ៤ ប្រការគឺ:

១ – ត្រូវឲ្យដឹងខ្លួនគ្រប់ខណៈដែលឈរ, ដើរ, អង្គុយ, ដេក, ស៊ី, ផឹក, ធ្វើ, និយាយ, គិត កុំឲ្យចិត្តភាយមាយ គឺខណៈដែលឈរក៏ឲ្យដឹងថា «យើងឈរៗ» លុះដឹងថាចិត្តខ្លួនមិននឹកឃ្លាតឆ្ងាយទៅក្នុងផ្លូវដទៃហើយ ទើបចាប់ផ្ដើមគិតរបស់ដែលខ្លួនត្រូវការយ៉ាងដទៃទៅទៀត ក្នុងវេលាដែលខ្លួនដើរ ឬអង្គុយ; ដេក, ស៊ី, ផឹក, ធ្វើ, និយាយ, គិតក៏ឲ្យដឹងខ្លួនដូចអធិប្បាយហើយក្នុងវេលាដែលខ្លួនឈរដែរ ។

២ – កុំសេពគប់នឹងមនុស្សវង្វេងព្រើន, ភ្លេចព្រើន ព្រោះនឹងធ្វើខ្លួនឲ្យទៅជាមនុស្សវង្វេងព្រើន, ភ្លេចព្រើនតាមគេផង ។

៣ – ឲ្យសេពគប់តែនឹងមនុស្សដែលមានស្មារតីចាំបានមាំមួនព្រោះនឹងធ្វើខ្លួនឲ្យទៅជាមនុស្សមានស្មារតីចាំបានមាំមួនតាមគេផង និងគេនឹងបានជួយដាស់តឿនខ្លួនក្នុងខណៈដែលខ្លួនវង្វេង, ភ្លេច មួយទៀត កាលបើខ្លួនឃើញគេចាំមាំមួនល្អ ក៏នឹងមានចិត្តកៀនក្នាសគេ ហើយប្រឹងធ្វើឲ្យជាមនុស្សចាំបានមាំមួនឡើង ។

៤ – ឲ្យយកចិត្តទុកដាក់តែក្នុងរៀនចាំ គឺឲ្យគិតប្រើដៅខ្លួនឯងរឿយៗ ថា យើងនឹងព្យាយាមធ្វើខ្លួនឲ្យទៅជាមនុស្សមានស្មារតីចាំបានម៉ាំមួន ។

កាលធ្វើតាមគោលទាំង ៤ នេះបានហើយ ទើបនឹងបានជាមនុស្សមានស្មារតីចាំបានមែនទែន មិនភ្លេចនឹងមិនគួររបស់ដែលខ្លួនធ្វើឬនិយាយ នឹងរៀនសូត្រមកហើយ ។

## ២ – វិជ្ជាកំចាត់ល្ងង់ខ្លៅ មាន ៧ ប្រការគឺ

១ - ឲ្យឧស្សាហ៍សាកសួររបស់ដែលខ្លួនមិនដឹងមិនចូលចិត្ត ។

២ - ឲ្យឧស្សាហ៍សំអាតរូបកាយ, សំលៀកបំពាក់ គ្រឿងប្រើប្រាស់ នឹងទីលំនៅឲ្យស្អាត កុំឲ្យប្រឡាក់កាក្រក់ ។

៣ - ឲ្យធ្វើរបស់ទាំង ៥ គឺ សេចក្តីជឿ សេចក្តីព្យាយាម សេចក្តីរឭក សេចក្តីតាំងចិត្ត សេចក្តីត្រិះរិះ ឲ្យកើតមានស្មើៗគ្នា កុំឲ្យតិចច្រើនជាងគ្នា ។

៤ - កុំសេពគប់នឹងមនុស្សល្ងង់ខ្លៅ មិនឈ្លាសវៃ ព្រោះនឹងធ្វើខ្លួនអ្នកសេពគប់ឲ្យល្ងង់ខ្លៅទៅតាមគេផង ។

៥ - ឲ្យសេពគប់តែនឹងមនុស្សមានប្រាជ្ញាឈ្លាសវៃ ព្រោះនឹងធ្វើខ្លួនអ្នកសេពគប់ឲ្យមានប្រាជ្ញាឈ្លាសវៃទៅតាមគេផង ។

២ – ឲ្យយកចិត្តទុកដាក់ក្នុងការស្រាវជ្រាវរកហេតុផលផ្សេងៗ ដែលខ្លួនបានជួបប្រទះ គឺកាលបានជួបប្រទះរបស់អ្វី ដែលខ្លួនមិនដឹងរឿង ឬមិនដឹងដើមចុងរបស់នោះ ត្រូវពិចារណាឲ្យទាល់តែបានដឹង កុំធ្វើព្រងើយកន្តើយ ។

៣ ឲ្យយកចិត្តទុកដាក់ក្នុងអ្វីដែលធ្វើឲ្យឈ្លាសវៃជានិច្ច ទោះបីធ្វើអ្វីក៏ដោយ ត្រូវតែខំឲ្យប៉ិនប្រសប់ក្នុងរបស់នោះ ដូចជាការបង្កាត់ភ្លើង កាលតែពេលដែលបង្កាត់ភ្លើង ត្រូវតែគិតពិចារណាថា ធ្វើដូចម្តេចទើបភ្លើងនឹងឆេះឆាប់ ខំគិតឲ្យទាល់តែចេះដឹងយល់ច្បាស់ក្នុងកិច្ចបង្កាត់ភ្លើង ដូច្នេះជាដើម ។

កាលបើធ្វើតាមគោលទាំង ៣ ប្រការនេះផុតហើយ ទើបអាចកំចាត់សេចក្តីល្ងង់ខ្លៅចេញបានជាប្រាកដ ត្រឡប់ទៅជាអ្នកមានប្រាជ្ញាឈ្លាសវៃប៉ិនប្រសប់មិនខាន ។

## ៣– វិធីកំចាត់សេចក្តីខ្ជិលច្រអូស មាន ១០ ប្រការ គឺ

១ – ឲ្យនឹកដល់ទោសរបស់សេចក្តីខ្ជិលថា « សេចក្តីខ្ជិលមិនល្អសោះឡើយ មានតែធ្វើឲ្យមនុស្សថោកទាបមួយយ៉ាង » ។

២ – ឲ្យនឹកដល់គុណរបស់សេចក្តីព្យាយាមថា « សេចក្តីព្យាយាមជារបស់ធ្វើឲ្យមនុស្សស្រួលបានសេចក្តីសុខសេចក្តីចំរើនគ្រប់វេលា » ។

៣ - ឲ្យនឹកដល់ផ្លូវជាដំណើររបស់មនុស្សថា «ផ្លូវជាដំណើររបស់មនុស្សដែលនឹងឲ្យបានសេចក្តីចេះដឹង ឲ្យបានសេចក្តីល្អ ឲ្យបានសេចក្តីសុខ សេចក្តីចំរើននោះ មិនមែនជារបស់ងាយទេ មនុស្សខ្ជិលច្រអូសមិនអាចនឹងធ្វើដំណើរទៅតាមបានឡើយ» កាលនឹកឃើញនេះហើយ ឲ្យនឹកតាំងចិត្តខ្លួនឯងថា «យើងត្រូវតែមានព្យាយាម យើងត្រូវតែប្រឹងប្រែង យើងមិនត្រូវរួញរាទេ» ។

៤ - ត្រូវគោរពចំពោះអាហារដែលខ្លួនបរិភោគ គឺកាលពេលដែលបរិភោគអាហារឲ្យនឹកថា «អាហារនេះមិនមែនជារបស់ដែលមនុស្សខ្ជិលច្រអូសត្រូវបរិភោគទេ ព្រោះជារបស់កើតមានឡើងដោយសេចក្តីព្យាយាមរបស់មនុស្ស ដូចបាយជាដើម ទម្រាំតែនឹងបានមកបរិភោគ អ្នកស្រែត្រូវតែធ្វើយ៉ាងលំបាកក្រៃលែង» កាលនឹកឃើញនេះហើយ ឲ្យនឹកប្រដៅខ្លួនឯងថា «យើងត្រូវតែធ្វើជាមនុស្សមានព្យាយាម យើងត្រូវតែធ្វើជាមនុស្សប្រឹងប្រែង យើងត្រូវតែធ្វើជាមនុស្សមិនរួញរា» ។

៥ ឲ្យនឹកដល់ផលដែលខ្លួនត្រូវបានអំពីសេចក្តីព្យាយាម គឺទ្រព្យជាលោកិយ ឬលោកុត្តរៈថា «បើយើងខ្ជិលច្រអូស ប្រាកដជាមិនបានទ្រព្យជាលោកិយ ឬលោកុត្តរៈសោះឡើយ» ហើយឲ្យនឹកប្រដៅខ្លួនដូចក្នុងទី ៤ ។

៦ - ឲ្យនឹកដល់គ្រូអាចារ្យដែលបង្ហាត់បង្រៀនបំណេះវិជ្ជាដល់ខ្លួនថា «លោកទាំងអស់នោះសុទ្ធតែជាអ្នកមានបំណេះវិជ្ជាល្អ សុទ្ធតែប្រាថ្នាចង់ឲ្យយើងបានល្អទាំងអស់ គ្មានចិត្តប្រទូស្តចង់ឲ្យយើងទៅជាមនុស្សថោកទាបឡើយ» ។

៧ - ឲ្យនឹកថា «យើងមានជាតិខ្ពង់ខ្ពស់ជាងសត្វតិរច្ឆាន យើងមិនគួរនឹងខ្ជិលច្រអូសទេ មិនគួរធ្វើខ្លួនឲ្យគ្មានសេចក្ដីអង់អាចដូចសត្វតិរច្ឆានឡើយ» ។

៨ - ឲ្យនឹកដល់មិត្រសំឡាញ់ជាអ្នកមានព្យាយាមដែលគេបានចេះដឹងបានល្អ បានសុខ បានចំរើនផ្សេងៗឲ្យឃើញថាសុទ្ធតែគេជាមនុស្សមានព្យាយាមទាំងអស់» ។

៩ - កុំសេពគប់នឹងមនុស្សខ្ជិលច្រអូស ឲ្យសេពគប់តែនឹងមនុស្សមានព្យាយាម ។

១០ - ត្រូវហាត់តតចិត្តឲ្យស្រឡាញ់សេចក្ដីព្យាយាម ឲ្យស្អប់ខ្ពើមសេចក្ដីខ្ជិលច្រអូសដូចជាខ្ពើមលាមក ។

កាលបើធ្វើតាមគោល ១០ ប្រការនេះបានហើយ មុខជានឹងកំចាត់សេចក្ដីខ្ជិលច្រអូសចេញបាន ។ បើនឹងប្រដៅកូនចៅឬសិស្សជាដើម ដែលខ្ជិលច្រអូសឲ្យត្រឡប់ទៅជាមនុស្សមានព្យាយាមវិញ ក៏ឲ្យប្រដៅ

កាមគោលការណ៍ ១០ ប្រការនេះចុះ តែឲ្យចេះប្រើ គឺកុំប្រើត្រង់ៗ តែម្តង ដូចប្រើក្នុងវេលាបរិភោគអាហារ ឬបរិភោគរួចហើយ មុនដំបូងត្រូវសួរថា «អាហារដែលយើងបរិភោគនេះជារបស់អ្នកខ្ជិលច្រអូស ឬអ្នកឧស្សាហ៍ធ្វើឲ្យកើតមានឡើងពីដើមដំបូង» សួរយ៉ាងនេះក៏បានបើគេមិនទាន់យល់ពាក្យសួរ ត្រូវពន្យល់ពីរឿងអាហារឲ្យស្តាប់ហើយសួរទៀត តើគេនឹងឆ្លើយដូចម្តេច បើគេឆ្លើយមិនត្រូវ ក៏កុំស្ដាប់ ចេះតែព្យាយាមសួរទៀត ទាល់តែគេឆ្លើយត្រូវថាជារបស់អ្នកឧស្សាហ៍ធ្វើឲ្យកើតមានឡើងហើយសួរតទៅទៀតថា «បើដូច្នោះ ខ្លួនឯងនឹងធ្វើជាអ្នកឧស្សាហ៍ ឬជាអ្នកខ្ជិល» កាលបើគេឆ្លើយថា «ខ្លួនខ្ញុំត្រូវតែធ្វើជាអ្នកឧស្សាហ៍» ដូច្នេះហើយឲ្យឈប់និយាយត្រឹមប៉ុណ្ណេះ ចាំគន់មើលតទៅទៀតថា គេនឹងឧស្សាហ៍ឬទេ បើគេមិនឧស្សាហ៍ ឲ្យជាសំនៀនរំឭកថា «នែឯងថានឹងធ្វើជាអ្នកឧស្សាហ៍ ហេតុអ្វីក៏បានជាឯងមិនធ្វើតាមសំដីដែលថាមកពីដើមនោះ» ទោះគេឆ្លើយក្តី សៀមក្តី យើងកុំនិយាយអ្វីតទៅទៀត ត្រូវគ្រាន់តែចាំសង្កេតមើលកិរិយាទៅខាងមុខ ហើយខំណែនាំប្រើតាមគោលដដែលៗ ទាល់តែឲ្យបានជាមនុស្សឧស្សាហ៍ ។

## ៤ – វិជ្ជាកំចាត់សេចក្តីតប់បិត្ត មាន ៦ ប្រការគឺ

១ ឲ្យនឹកដល់សេចក្តីល្អរបស់ខ្លួនថា «យើងបានធ្វើអំពើល្អយ៉ាងនោះៗ ក្នុងវេលានោះៗ ឬនឹកដល់ការដែលខ្លួនបានជួយសង្គ្រោះអ្នកដទៃ

(មានត)

ពន្ធអាស៊ីទ្វីប

ឃ្លាំងនិពន្ធមន្ត្រី ញ៉ុក - ថែម ប្រែប្រួល

(តមក)

ហើយមានចំរឹងយ៉ាង ១ ជាន់ទៀតផង នៅក្បែរទ្វារនិមួយ ៗ ក៏មានអ្នកយាមសុចរិតទៀងត្រង់ចាំថែរក្សា ហើយតាមព្រះរាជបញ្ជារបស់ព្រះរាជាត្រាស់ថា «កុំបណ្ដោយឲ្យអ្នកណាមួយទៅមកឲ្យសោះ ទុកជាព្រះរាជបុត្ររបស់យើងក៏ដោយ អ្នកទាំងអស់គ្នាត្រូវទទួលខុសត្រូវដោយក្បាលរបស់អ្នកទាំងអស់គ្នា» ។

## បរិច្ឆេទទី ៣

ព្រះពុទ្ធកុមារជាម្ចាស់យើងទ្រង់គង់សម្រាន្ត ក្នុងព្រះរាជវាំងជាក្រុមក្សត្រ មានតែសេចក្ដីរីករាយនិងសេចក្ដីស្នេហា ទ្រង់មិនដែលស្គាល់សេចក្ដីទុក្ខព្រួយ, សេចក្ដីស្រេកឃ្លាន សេចក្ដីក្រៀមក្រំ, ចាស់ជរានិងមរណៈសោះឡើយ ប៉ុន្តែក្នុងខណៈដែលទ្រង់ផ្ទុំស្កល់ ទ្រង់ព្រះសុបិនថា ព្រះវិញ្ញាណបានត្រេចរត់ទៅកាន់ផ្ទៃសមុទ្រដ៏និតល្ហប់ ហើយបានទៅដល់ត្រើយខាងនាយ ទើបភ្ញាក់ឡើងក្រោយដែលបានចេញដំណើរយ៉ាងឆ្ងាយហាក់ ទ្រង់មានការចាំយ៉ាងចំឡែកក្នុងការធ្វើដំណើរយ៉ាងនឹកតនិងល់នោះ មានកាលគ្រា ១ ខណៈដែលព្រះអង្គជាព្រះសារ

ហើយលើព្រះទ្រូងរបស់ព្រះនាងយសោធរា សឹងមានព្រះហស្តនាំឲ្យកើតសម្ផស្សគួរស្នេហា ហើយទ្រង់ផ្ទំលក់ទៅ ស្រាប់តែទ្រង់ស្រែកឡើងក្នុងខណៈនោះថា «ឱក្រកឡរបស់ខ្ញុំ ឱ! ឱក្រកឡ, ខ្ញុំបានឮ, ខ្ញុំដឹង, ខ្ញុំមក!» ទើបព្រះនាងយសោធរាទូលសួរថា «កើតអ្វីព្រះអង្គ ម្ចាស់ថ្លៃខ្ញុំអើយ? ព្រះនាងខានព្រះនេត្របើកធំដោយការងឿងឆ្ងល់ព្រះទ័យ: ពីព្រោះក្នុងវេលាគ្រានោះ ព្រះភក្ត្រព្រះរាជកុមារ ប្រកបដោយការតក់ស្លុតរន្ធត់ព្រះទ័យ ហើយមានព្រះភ័ក្ត្រហាក់ដូចជាព្រះជាម្ចាស់អង្គមួយ ទើបទ្រង់ញញឹមឡើងវិញ ដើម្បីបន្ទោបង់ការសោយសោករបស់ព្រះទេវី ហើយទ្រង់សុំឲ្យបន្ទន់ភ្លេងពិណតទៅទៀត ឧបមាថ្ងៃ ១ គេនាំយកពិណផ្លែឃ្លោកមានខ្សែយកទៅដាក់ត្រង់ចន្លនដែលមានខ្យល់បក់ល្ហុម ឲ្យកើតសូរសំឡេងភ្លេងដោយកំទប់នឹងខ្យល់ - ពីព្រោះខ្យល់ធ្វើឲ្យកើតសំឡេងភ្លេងយ៉ាងចំឡែក លើខ្សែព្រាត់នោះ អស់អ្នក ដែលអង្គុយជុំវិញក៏បានឮតែសំឡេងភ្លេងដូច្នោះដែរ ប៉ុន្តែព្រះសិទ្ធត្ថរាជកុមារទ្រង់បានឮពួកទេវតាលេងភ្លេងទៅវិញ ហើយសំដីដែលពួកទេវតាស្រែកច្រៀងមកប៉ះពាល់ដល់ព្រះសោតប្រសាទនោះដូចតទៅនេះ

«យើងជាសំឡេងខ្យល់បក់ដែលបក់ឥតការឈប់សម្រាក តែមិនដែលបានដូចចិត្តការឈប់សម្រាកនោះឡើយ សូមទ្រង់ទតមើលចុះ ខ្យល់មានចំនួនដូចម្ដេច ជីវិតដែលមានសេចក្ដីស្លាប់ជាធម្មតា ក៏មាន

ចំណងជាប់ពោះវៀន គឺការសង្រេនសង្រៃ, ការផឹកផ្ទើមធំ ការយំសោក ការទន្ទូកទន្ទេញ ការតស៊ូ» ។

« យើងមិនគប្បីងប្រល់ដល់ហេតុផលនៃការរស់នៅរបស់យើង ដើមហេតុនៃជីវិត ដើមចមរបស់ជីវិត ពួកយើងក៏ដូចជាទ្រង់ដែរ គឺជាភាពចំលាចលោះសូន្យ ពុះឲ្យយើងសប្បាយដូចម្ដេចកើត ក្នុងកន្ទុកដែលមានតែសេចក្ដីប្រែប្រួលមិនស្រាកនេះ?

« ពុះទ្រង់រីករាយដូចម្ដេចទៅ នៅក្នុងសេចក្ដីសុខដែលបត់តទៀងតាក់នេះ? ឱ! បើសេចក្ដីស្នេហាមាននៅក៏អាចធ្វើឲ្យមានការស្រួលសប្បាយមែន ប៉ុន្តែងជីវិតនេះមានទបមាដូចជាខ្យល់, របស់ទាំងពួងមានតែជាសំទៀងដែលលាន់ក្ពុទៀង លើខ្យល់ដែលមានលក្ខណៈញាប់ញ័រប៉ុណ្ណោះ» ។

« ឱ! ព្រះកជនរសរបស់ព្រះមាន់មា យាទៅអើយ! គឺព្រោះតែយើងតែងត្រេចគ្រាត់ទៅលើពស្ដា ដែលយើងធ្វើឲ្យកើតស្បូវពិតទៀង លើខ្យល់ទាំងនេះ យើងឥតស្រែកច្រៀងយ៉ាងសប្បាយចិត្តទេ គឺព្រោះយើងមើលឃើញតែសេចក្ដីទុក្ខទាំងអស់ នៅក្នុងប្រទេសទាំងពួង មានតែដូនក្លែរបោម ហើយមានតែពុតមួយដោយទៅវាយអស់សង្ឃឹម» ។

« ប៉ុន្តែយើងត្រូវបណ្ដេញការសង្រេនសង្រៃ របស់យើងចេញ គឺព្រោះប្រសិនបើមនុស្សទាំងឡាយគាបបេះដីនិជា ជីវិតនេះជារបស់គត

ខ្លឹមសារ បើទុកជាគេគាបបង្អាប់ពួកគេឲ្យឈប់អណ្តែតទៅបាន ឬបង្អាក់ខ្សែទឹកឲ្យឈប់ហូរបានក៏ដោយ » ។

« ប៉ុន្តែទ្រង់ដែលត្រូវតែជាអ្នកជួយស្រោចស្រង់លោក, ពេលវេលាក៏កាន់តែជិតណាស់ហើយ! លោកទាំងមូល កំពុងរង់ចាំជំនួយដោយការក្រហល់ក្រហាយ លោកដ៏ធំធេងទាំងមូលអន្ធការកំពុងរលេះរលក់ក្នុងរង្វង់នៃសេចក្តីទុក្ខព្រួយ, ឱ ព្រះរាជឱរសព្រះនាងមាយា, សូមព្រះអង្គកើតឡើង, សូមព្រះអង្គលើកឡើង, ព្រះអង្គលែងឈប់សម្រាកព្រះអង្គទៅ!

« យើងជាសំឡេងនៃខ្យល់បក់ សូមព្រះអង្គទ្រង់តំណើរ, ឱ ព្រះពុទ្ធបុត្រ ដើម្បីឲ្យបាននូវទីងការសម្រាករបស់ព្រះអង្គ, សូមទ្រង់លះបង់សេចក្តីស្នេហា ដើម្បីមេត្តាដល់សព្វសត្វដែលគួរស្រឡាញ់, សូមទ្រង់លះបង់គ្រឿងឥស្សរិយយសក្សត្រចេញ ដើម្បីបន្ទាបង់ការសេវ្រេងសាស្ត្រ ទីនដើម្បីបំពេញវិមុត្តិធម៌ »

« ដូច្នេះ ទើបយើងត្អូញថ្ងូរលើខ្យល់ប្រាប់ដើម្បីឲ្យព្រះអង្គដែលមិនទាន់ស្គាល់របស់អ្វីៗលើពិភពលោក ដូច្នេះ ទើបយើងនិយាយ, យើងបំអនឡូកឡូយចំពោះសភាពដែលទ្រង់ក្រសាលឥតទៀងទាត់នេះ » ។

តមកក្រោយទៀត វេលាព្យាប១ ព្រះសិទ្ធត្ថទ្រង់គង់កណ្តាលព្រះលានដ៏ធំតាយ ទ្រង់ចាប់ព្រះហស្តព្រះនាងយសោធរ (គោតមី) មានកុមារីស្រីក្រមុំម្នាក់បានតំណាលរឿងព្រេងបុរាណ ដើម្បីឲ្យកើត

ក្រែងក្រោយទៀតក្នុងយាមព្រលប់សន្ធ្យា ។ ព្រមទាំងមេឃនៅក្នុងជួរ ត្រ៊ី នៅខណៈដែលនាងបៀងយាំងពីកោះ ។ រឿងនោះជាទិដ្ឋានប្រគប ដោយសេចក្តីស្នេហា ជាមានសេះ ១ យ៉ាងវិសេស ហើយមានប្រទេស ១ នោះនៅឆ្ងាយដាច់ស្រយាល ដែលមានប្រជាជនសំបុរស្រអាប់ៗ ហើយ ជាស្រុកដែលមានព្រះអាទិត្យធំយប់លិចចុះទៅក្នុងសមុទ្រ ។ កាលណោះព្រះរាជកុមារទ្រង់ផ្ចង់ផ្ចើមធម៌មានព្រះបន្ទូលថា «ចិត្រា, នាងរំលឹកខ្ញុំអំពីចំរៀងខ្យល់ដែលលាន់ឮឡើងក្នុងវែង ព្រមទាំងរឿងកំរោយ៉ាងពីកោះ ចូរព្រះនាងប្រទានក្បួនមុក្តានៅនាងនេះចុះ ចូរនាងឱយាងមកមើល តើនៅមានលោកជំជូលាយណាសំនែងឬ? តើមានប្រទេសណាមួយដែលមើលឃើញព្រះអាទិត្យធំ អណ្តែតនៅក្នុងពពកឬទេ ? នៅប្រទេសនោះសោកតើជួនចិត្តរបស់គេដូចជាយើងដែរឬទេ ជាពួកមនុស្សមានចិត្តច្រើនណាស់, ឥតនរណាស្គាល់ តែប្រហែលមានទុក្ខវេទនា ដែលយើងអាចនឹងជួយគេបាន ប្រសិនបានស្គាល់ពួកវាំងនោះ? តែនឹងមានជារឿយៗ កាលណាព្រះអាទិត្យរះឡើងនៅទិសខាងកើត តែងចាំងរស្មីពណ៌មាសនៅព្រាលខ្ពស់ ខ្ញុំគិតបីដោយជឿចូលថា នៅចុងបំផុតលោកឯណោះ ក្នុងចំណោមពួកគេទិសខាងកើត គង់មានគេណាមួយជាដំបូងដែលបានថ្វាយបង្គំរស្មីព្រះអាទិត្យ, មានជារឿយៗដែរ ដែលខ្ញុំបាននៀតកើយក្នុងព្រះហស្តនាង, ឱនព្រះទ្រព្រះនាង, ឱ! ករយោ

ជាទីស្នេហា ចិត្តខ្ញុំតែងក្រវល់ក្រវាយដោយទុក្ខព្រួយនៅពេលព្រះអាទិត្យ
អស្តង្គតទៅខ្ញុំចង់ទៅតាមព្រះអាទិត្យនៅទិសខាងលិចដែលលិចបាត់ទៅនោះ
ដើម្បីទៅមើលប្រជាជននៅទិសខាងលិច ។ នៅទីនោះ ត្រូវតែមាន
មនុស្សប្រុសល្អដែលយើងគួរស្រឡាញ់ គង់មិនមានយ៉ាងដូចទៅទៀតក្រៅ
អំពីនោះទេ ? នៅក្នុងខណៈនេះឯង ខ្ញុំមានសេចក្តីព្រួយព្រោះបើបានបុត្ត
ព្រះនាង គឺនៅតែមិនស្បើយទុក្ខ ឱ! ព្រះរាជកុមារី, ឱ បិតា! នាង
ដែលបានស្គាល់ប្រទេសវិសេស តើអាជានយន្តក្នុងរឿងរបស់នាង
នោះចង់ទុកនៅទីណា? ចុះមិនគាបយកកំណងខ្ញុំដាក់លើខ្នងវាហើយបំផាយ
ទៅៗ ដើម្បីទៅមើលផែនដីដ៏ធំទូលាយនោះទេឬ? ឬដោយហោចទៅ
បើខ្ញុំបានស្លាបគ្នាត សត្វសុតំរង់នេះហើយដែលបានទទួលមត៌ករបស់
ប្រទេសដ៏ធំទូលាយជាងរបស់ខ្ញុំទៅទៀត តើបើដូចជាខ្លួនខ្ញុំនឹងឈានយក
កំណាប់ទ្រព្យលើពពូលភ្នំហិមាលយ៉ា ដែលមានរស្មីភ្លឺដោយហិមៈ
ដែលមានសិម្ពុជាតិកុលាប ដើម្បីពោលភ្នែកត្រចៀតមើលទៅនគរទាំង
ឡាយដែលនៅជុំវិញ, ចុះហេតុអ្វីបានជាខ្ញុំមិនដែលបានឃើញសោះ
តាំងមិនដែលនាំឲ្យខ្ញុំបានឃើញទៀតផង? ចូរប្រាប់មកខ្ញុំមើល តើរបស់
ដែលនៅខាងក្រៅប្រាសាទម៉ែទ្វានោះមានអ្វីខ្លះ? (មានត)

## មដ្ឋកុណ្ឌលិនិទាន

### ព្រះមហាកែវ-ណា ត្រី សុវណ្ណោ

(តមកពីលេខ ១២ ឆ្នាំ ១៩៤៨)

អចរិយំ វត អព្ភុតំ

អញ្ជលិកម្មស្ស អយមីទិសោ វិបាកោ

អហំបិ មុទិតមនោ បសន្នចិត្តោ

អជ្ជេវ ពុទ្ធំ សរណំ វជាមិ ។

អើហ្ន៎! អស្ចារ្យពេក ហេតុចំឡែកមិនដែលមាន

អំពីហស់បុណណ ឥឡូវមានទើបកើតថ្មី ។

ផលអញ្ជលិកម្ម នេះឧត្តមល្អពិសី

នាំឲ្យបានសួស្តី សិរីសុខសអស្ចារ្យ ។

ខ្ញុំមានមនោរម្យ រីករាយដ៏ឥតឧបមា

ទាំងមានចិត្តជ្រះថ្លា ដោយរាបរស់អ្នក ។

ចាប់ពីថ្ងៃនេះទៅ ខ្ញុំដល់នូវព្រះពុទ្ធ

យកជាសរណៈ ការៈមិនខានឡើយ ។

មាណពពោលដាស់តឿនគ្រែនលំដថា ៖

អជ្ជេវ ពុទ្ធំ សរណំ វជាមិ

ធម្មញ្ច សង្ឃញ្ច បសន្នចិត្តោ

តថេវ សិក្ខាបទានិ បញ្ច
អខណ្ឌផុល្លានិ សមាទិយស្សុ
បាណាតិបាតា វេរមស្សុ ខិប្បំ
លោកេ អទិន្នំ បរិវជ្ជយស្សុ
អមជ្ជបោ នោ ច មុសា ភណាហិ
សកេន ទារេន ច ហោហិ តុដ្ឋោ ។

អ្នកឯងត្រូវមានចិត្តជ្រះថ្លា    គប់រកសរណគមនៈត្រៃ
ព្រះពុទ្ធព្រះធម៌ព្រះសង្ឃថ្លៃ    ចាប់តាំងពីថ្ងៃនេះកុំខាន ។
ម្យ៉ាងទៀតត្រូវអ្នកចំពេញ    បញ្ចសិក្ខាបទកល្យាណ
គឺ កុំសម្លាប់សត្វតិរច្ឆាន    ដែលមានជីវិតពិតជារស់ ។
ចូរកុំកាន់យកទ្រព្យដែលគេ    មិនបានឲ្យទេក្នុងលោកសោះ
ត្រូវអ្នកត្រេកអរសោមនស្ស    ប្រពន្ធជារបស់នៃអាត្មា ។
ចូរកុំពោលពាក្យដែលមិនពិត    ទាំងកុំប្រព្រឹត្តផឹកស្រា
ជាដាច់កុំឲ្យដាច់សោះសា    ធុះធ្លាយសិក្ខាបទណាឡើយ ។

អចិនបុត្រព្រាហ្មណ៍បានទទួលកាន់ដោយល់ព្រមថា នឹងប្រតិបត្តិតាមដោយពាក្យជាគាថាដូច្នេះ ៖

អត្ថកាមោសិ មេ យក្ខ ហិតកាមោសិ ទេវតេ
ករោមិ តុយ្ហំ វចនំ ត្វមសិ អាចរិយោ មម

ឧបេមិ សរណំ ពុទ្ធំ ធម្មញ្ចាបិ អនុត្តរំ
សង្ឃញ្ច នរទេវស្ស គច្ឆាមិ សរណំ អហំ
បាណាតិបាតា វិរមាមិ ខិប្បំ
លោកេ អទិន្នំ បរិវជ្ជយាមិ
អមជ្ជបោ នោ ច មុសា ភណាមិ
សកេន ទារេន ច ហោមិ តុដ្ឋោ

បពិត្រទេពមហាបុរស    អ្នកប៉ងគុណខ្ពស់សង្គ្រោះដល់ខ្ញុំ
ពន្យល់ប្រដៅប្រយោជន៍ឧត្តម    ចង់ឲ្យខ្លួនខ្ញុំកាន់ធម្មក្រឹត្យា
ខ្ញុំនឹងធ្វើតាមពាក្យអ្នកបវរ    ខ្ញុំទុកអ្នកជាអាចារ្យខ្ញុំស្មោះ
ខ្ញុំនឹងដល់នូវព្រះពុទ្ធគោតម    ជាសរណគមន៍ដោយសោមនស្ស
ព្រមទាំងព្រះធម៌ជារត្នខ្ពង់ខ្ពស់    នឹងគេរបស់អ៊ីប្រែបពុំបាន
ទាំងអរិយសង្ឃជាស្រែបុណ្យមាន    ជាបុត្រទ្រង់ញ្ញា ណានរៈទេពពិត
ជាសរណៈស្មើដោយជីវិត    ព្រមទាំងប្រព្រឹត្តកាន់សិក្ខាបទ
គឺខ្ញុំវៀរចាកការសម្លាប់សត្វ    មិនហ៊ានបំបាត់លួចទ្រព្យធនគេ
ជាម្ចាស់ទ្រព្យមិនឲ្យក្នុងលោកនេះ    មិនពោលវៀចវេរដោយពាក្យមុសា
ខ្ញុំមិនប្រព្រឹត្តផឹកទឹកសុក    ខ្ញុំសោមនស្សតែនឹងប្រពន្ធ
នៃខ្លួនតែម្យ៉ាងមិនលួចស្ត្រីស្នន់    ទារីរបស់ផងដែលគេហៅហៅ
បញ្ចសិក្ខាបទនេះប្រពៃ    ខ្ញុំកាន់រាល់ថ្ងៃមិនឲ្យធ្លុះធ្លាយ ។

លំដាប់នោះ មដ្ឋកុណ្ឌលីទេវបុត្រ ពន្យល់អទិន្នបុព្វកព្រាហ្មណ៍ថា «ទ្រព្យសម្បត្តិក្នុងផ្ទះរបស់អ្នកមានសម្បូណ៌សម្បើមណាស់ អ្នកចូរយកចែកថ្វាយទានចំពោះព្រះសាស្ដាចារ្យ រួចស្ដាប់ធម៌ទេសនា ព្រមទាំងសាកសួរប្រស្នាធម៌អាថ៌ណាមួយ ចំពោះព្រះអង្គទៅ" ថាហើយក៏ហោះទៅឋានទេវលោកវិញបាត់ទៅ ។ ចំណែកឯអទិន្នបុព្វកព្រាហ្មណ៍ ក៏ត្រះប្រញាប់ប្រញាល់ត្រឡប់ទៅផ្ទះវិញ ប្រាប់ប្រពន្ធថា ៖

មាសភាពជាសំឡាញ់ ផ្សាយពេញអាកាសា
និមន្តមហាសមណ មកសាកសួរនូវប្រស្នា ។
ចូរនាងរៀបតុបតែង ផ្ទះសំបែងគ្រឿងសក្ការៈ
បូជាឲ្យបាន ណាស្រីកុំខាន ។

ស្រុះប្រាប់ប្រពន្ធហើយក៏ទៅកាន់វត្តជេតពន មិនថ្វាយបង្គំមិនធ្វើបដិ-សណ្ឋារៈទៅកេព្រះដ៏មានព្រះភាគទេ គ្រាន់តែឈរក្នុងទីមួយហើយនិមន្តថា ៖

បពិត្រមហាស្រមណ៍ នាមគោតមដ៏ចំរើន
ថ្ងៃស្អែកសូមក្រើន ស្ដេចទៅសោយភត្តាហារ ។
ក្នុងផ្ទះរបស់ខ្ញុំ ព្រមទាំងក្រុមសង្ឃបរិវារ
ចំនួនក៏មិនថា សូមមេត្តាកុំខានឡើយ ។

ព្រះមុនិន្ទពុទ្ធសម្តេចទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ។ អទិន្ន-បុព្វកព្រាហ្មណ៍លុះបានឮថាព្រះទសពលទ្រង់ទទួលនិមន្តហើយ ក៏ប្រញាប់ប្រញាល់ត្រឡប់ទៅផ្ទះ ជួយចាត់ចែងសក្ការបូជានិងខាទនីយភោជនីយាហារប្រណីតៗ ។ វេលាព្រឹកថ្ងៃស្អែកឡើង ព្រះបរមសាស្តាបរិវារដោយមានភិក្ខុសង្ឃជាបរិវារ ទ្រង់ស្តេចយាត្រាទៅកាន់ផ្ទះអទិន្នបុព្វក: គង់លើបញ្ញត្តាសនៈ, ឯអទិន្នបុព្វកព្រាហ្មណ៍ក៏អង្គាសភត្តាហារថ្វាយដោយគោរព ។ ក៏ក្នុងពេលនោះពួកមហាជនបានប្រជុំគ្នាជាពួកជាក្រុម ។ ពួកជនជាមិច្ឆាទិដ្ឋិប្រជុំជជែកគ្នាថា "ថ្ងៃនេះ យើងនឹងបានឃើញអទិន្នបុព្វកព្រាហ្មណ៍សាកសួរប្រស្នាផ្ចាញ់ផ្ចាល់ព្រះសមណគោតម" ពួកជនជាសម្មាទិដ្ឋិប្រជុំជជែកគ្នាថា «ថ្ងៃនេះយើងនឹងបានឃើញវិស័យក៏សមារបស់ព្រះពុទ្ធ និងដំណើរលីលាយាត្រារបស់ព្រះពុទ្ធដែលជាបុគ្គលគួរអ្នកផងចង់ឃើញ» ។

កាលព្រះសម្ពុទ្ធទ្រង់សោយភត្តរួចស្រេចហើយ អទិន្នបុព្វក-ព្រាហ្មណ៍ក៏ចូលទៅអង្គុយជិតព្រះសាស្តាហើយសាកសួរប្រស្នាថា «បពិត្រព្រះគោតមដ៏ចំរើន, បើគេមិនបានឲ្យទាន មិនបានបូជា មិនបានស្តាប់ធម៌គាថា មិនបានរក្សាឧបោសថទេ គ្រាន់តែញុំាងចិត្តឲ្យជ្រះថ្លាចំពោះព្រះអង្គតែម្យ៉ាង តើអាចទៅកើតក្នុងស្ថានសួគ៌បានឬទេ? ។ ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់តបថា «ម្នាលព្រាហ្មណ៍ ព្រោះហេតុអ្វី

អ្នកក៏សួរតថាគត, ក្រែងដំណើរនេះ កូនអ្នកឈ្មោះមដ្ឋកុណ្ឌលីបាន ប្រាប់អ្នកហើយថា ខ្ញុំគ្រាន់តែបង្អោនចិត្តមកជ្រះថ្លាចំពោះតថាគត ប៉ុណ្ណោះក៏បានទៅកើតក្នុងសួគ៌ រួចហើយឬ? បពិត្រព្រះគោតមដ៏ចំរើន ចុះប្រាប់អំពីអង្កាល់? ។ ម្នាលព្រាហ្មណ៍ ក្រែងក្នុងថ្ងៃម្សិលមិញ អ្នកទៅឯព្រៃស្មសានហើយផ្គងដើមដៃយំស្តាយកូន ក្នុងទីជិតគល់ខ្ទមដុតខ្មោចកូននោះ ហើយបានឃើញបុរសកំឡោះម្នាក់មកយំជិតអ្នកនោះដែរ អ្នកនឹងបុរសកំឡោះនោះបាននិយាយឆ្លើយឆ្លងគ្នាទៅវិញទៅមក មិនមែនឬ? » រួចព្រះសាស្តាទ្រង់សំដែងរឿងកំរែមដ្ឋកុណ្ឌលីសព្វគ្រប់ ហើយទ្រង់ត្រាស់ទៅនឹងព្រាហ្មណ៍នោះថា «ម្នាលព្រាហ្មណ៍ ពួកជនដែលបានទៅកើតក្នុងឋានសួគ៌ ព្រោះផលដែលកើតអំពីញុំាងចិត្តឲ្យជ្រះថ្លាក្នុងតថាគត មិនមែនមានត្រឹម ១ រយ ឬ ២ រយនាក់ទេ មានច្រើនណាស់ ទីនគណនាត្រាកប់ពុំបានឡើយ » ។

កាលព្រះសាស្តាបរិយាយទ្រង់ត្រាស់ដូច្នេះហើយ, មហាជនមានសេចក្តីងឿងឆ្ងល់ជាខ្លាំង ព្រះអង្គទ្រង់ជ្រាបថាមហាជនសង្ស័យដូច្នោះ ក៏ធ្វើអធិដ្ឋានថា «មដ្ឋកុណ្ឌលីទេវបុត្តចូរចុះមកព្រមទាំងវិមាន» ។ មដ្ឋកុណ្ឌលីទេវបុត្តជ្រាបព្រះហឫទ័យនៃព្រះសម្ពុទ្ធហើយ ក៏រៀបចំខ្លួន តែងអត្តភាពមានប្រមាណ ៣ គាវុតដោយទិព្វាភរណៈ ហើយក៏មកព្រមទាំងវិមាន ដល់ហើយក៏ចុះចាកវិមានចូលមកធ្វើអភិវន្ទគារ

ចំពោះព្រះសាស្តាប្រថាប់នៅក្នុងទីដ៏សមគួរ ។ ព្រះសាស្តាទ្រង់មាន ព្រះពុទ្ធដីកាសួរថា ៖

អភិក្កន្តេន វណ្ណេន យា ត្វំ តិដ្ឋសិ ទេវតេ
ឱភាសេន្តី ទិសា សព្វា ឱសធី វិយ តារកា
បុច្ឆាមិ តំ ទេវ មហានុភាវេ
មនុស្សភូតា កិមកាសិ បុញ្ញំ

ម្នាលទេវបុត្ត អ្នករូបល្អ មានយសបវរមានរស្មី
ដែលចាំងភ្លាំងទិសចាំងគ្រប់ទី ឲ្យភ្លឺព្រឹមព្រាយហើយឋិតនៅ ។
ដូចជាឱសធីតារា ភ្លឺផ្លេកអស្ចារ្យថ្លាសន្ធៅ
រស្មីត្រសែតអណ្តែតទៅ ឋិតនៅលើអាកាសវេហាស៍ ។
នែ៎ទេវបុត្តទេពបុរស មានភាពដ៏ខ្ពស់ក្នុងត្រៃភព
តថាគតសួរអ្នកកាលណា យោនយេនកើតជាមនុស្សលោកនោះ ។
តើអ្នកបានធ្វើបុណ្យដូចម្តេច ទើបបានសម្រេចភាពខ្ពង់ខ្ពស់
ប្រសើរឧត្តមសមសក្តិយស គួរប្រាប់ចំពោះតថាគត ។ ។

លំដាប់នោះ ទេវបុត្រក្រាបទូលថា ៖

បពិត្រព្រះទ្រង់យស, សម្បត្តិខ្ពស់ខ្ពង់ថ្លៃថ្លា
នេះគឺខ្ញុំករុណា បានដោយសារចិត្តបសាទ ។ (ម៉ាគត)

## អំពីតាំងចៅអធិការនិងគ្រូសូត្រថ្មី

(តមក)

---

សញ្ញាប័ត្រលេខ ១៥៧ ចុះថ្ងៃ ៣ ១០ ២ ឆ្នាំជូតសំរិទ្ធិស័ក តាំងលោកគ្រូ ខុន-ចិត នាមឆាយាធម្មត្ថេរ កើតឆ្នាំកុរអាយុ ២៦ វស្សា ៣ ជាគ្រូសូត្រស្តាំ វត្តខ្នារ ឃុំខ្នារស ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។

សញ្ញាប័ត្រលេខ ១៥៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ក៉យ-ជ័យ នាមឆាយា មង្គលត្ថេរ កើតឆ្នាំខាល អាយុ ២៣ វស្សា ២ ជាគ្រូសូត្រឆ្វេង នៅវត្ត-ឃុំ-ស្រុក-ខេត្ត ដូចខាងលើ ។

សញ្ញាប័ត្រលេខ ១៥៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គង់-ង៉ួន នាមឆាយា វិនយត្ថេរ កើតឆ្នាំច អាយុ ៥១ ជាចៅអធិការវត្តបន្ទាយមៀន ឃុំមៀន ស្រុកកោះសូទិន ខេត្តកំពង់ចាម ។

សញ្ញាប័ត្រលេខ ១៦០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ទាំ-សាន នាមឆាយាវត្តត្ថេរ កើតឆ្នាំច អាយុ ៣៩ វស្សា ១៩ ជាគ្រូសូត្រស្តាំនៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ១៦១ ចុះកាលបរិច្ឆេទដដែលតាំងលោកគ្រូឡុង-ឡាយ នាមឆាយា ឥន្ទវិនយ: កើតឆ្នាំជូត អាយុ ៣៧ វស្សា ១៧ ជាចៅអធិការវត្តខ្នារ ឃុំខ្នារស ស្រុកស្រីសន្ធរកណ្តាល ខេត្តកំពង់ចាម ។

សញ្ញាប័ត្រលេខ ១៦២ ចុះថ្ងៃ ៤ ᧡ ៦ ឆ្នាំជូតសំរឹទ្ធិស័ក តាំងលោកគ្រូ ធន់-ស៊ុម នាមធាយា ធម្មទេសរ កើតឆ្នាំរោង អាយុ ៣៣ វស្សា ១២ ជាចៅអធិការវត្តរំលេច ឃុំរំលេច ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ១៦៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៊ុន-អន នាមធាយា សុវណ្ណបញ្ញោ កើតឆ្នាំខាល អាយុ ២៩ វស្សា ៨ ជាគ្រូសូត្រស្តាំ វត្តបារ ឃុំរំលេច ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ១៦៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ជួន-មួន នាមធាយា ធម្មបញ្ញោ កើតឆ្នាំរកា អាយុ ២៧ វស្សា ៨ ជាគ្រូសូត្រឆ្វេង នៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ១៦៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គល់-ពិល នាមធាយា តិស្សបញ្ញោ កើតឆ្នាំមមី អាយុ ៣១ វស្សា ៩ ជាចៅអធិការវត្តហោរ៉េ ឃុំសំបូណ៌ ស្រុកសំបូណ៌ ខេត្តក្រចេះ ។

សញ្ញាប័ត្រលេខ ១៦៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៊ុប ណុប នាមធាយា បុនទេសរ កើតឆ្នាំឆ្លូវ អាយុ ៣៦ វស្សា ៩ ជាចៅអធិការវត្តវិហារគោក ឃុំសំបូណ៌ ស្រុកសំបូណ៌ ខេត្តក្រចេះ ។

សញ្ញាប័ត្រលេខ ១៦៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ជា-ព្រំ នាមឆាយាសុវេទនគោ កើតឆ្នាំរកា អាយុ ៤១ វស្សា ១៩ ជាចៅអធិការវត្តអភោន្នរង្សិកម ឃុំកំពង់តាម ស្រុកសំបូណ៌ ខេត្តក្រចេះ ។

សញ្ញាប័ត្រលេខ ១៦៨ ចុះថ្ងៃ ៣ [illegible] ៩ ឆ្នាំជូតសំរិទ្ធិស័ក តាំងលោកគ្រូ គង់-ស៊ុន នាមឆាយា ឥន្ទជោត កើតឆ្នាំខាលអាយុ ៦០ វស្សា ៣៩ ជាចៅអធិការវត្តប្រជុំវង្ស ឃុំដីពោ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។

សញ្ញាប័ត្រលេខ ១៦៩ ចុះថ្ងៃ ៦ [illegible] ៩ ឆ្នាំជូតសំរិទ្ធិស័ក តាំងលោកគ្រូ ម៉ុច-ខាន់ នាមឆាយាសុវណ្ណគោ កើតឆ្នាំកោរ អាយុ ៥៤ វស្សា ៣០ ជាចៅអធិការវត្តតាហង់ ឃុំអណ្តូងពោធិ៍ ស្រុករមាសហែក ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ១៧០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ដៃ-យុត នាមឆាយា ធម្មប្បញ្ញោ កើតឆ្នាំកុរអាយុ ៤៦ វស្សា ៦ ជាគ្រូសូត្រស្តាំ វត្តកំពង់ត្រាច ស្រុករមាសហែក ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ១៧១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៉ាក់-ខាន់ នាមឆាយា ធម្មប្បញ្ញោគោ កើតឆ្នាំច អាយុ ៣៩ វស្សា ១៨ ជាចៅអធិការវត្តក្រពាំងធំ ឃុំអង្គព្រះរស្រ ស្រុករមាសហែក ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ១៧២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ុំ-យ៉ាន នាមធាយា សុវណ្ណប្បញ្ញោ កើតឆ្នាំរកា អាយុ ២៨ វស្សា ៨ ជាគ្រូសូត្រស្តាំវត្តត្រពាំងធំ ឃុំឥន្ទព្រះស្រែ ស្រុករមាសហែក ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ១៧៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ទៀវ-សុខ នាមធាយា បទុមប្បញ្ញោ កើតឆ្នាំមមី អាយុ ៣១ វស្សា ១០ ជាចៅអធិការវត្តព្រៃយអំពិល ឃុំក្បាលកោះ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ។

សញ្ញាប័ត្រលេខ ១៧៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ស-ឌិន នាមធាយា មហាឧត្តរាផ្លា កើតឆ្នាំកុរ អាយុ ២៦ វស្សា ៦ ជាចៅអធិការវត្តសន្ធរ ឃុំកំពង់ហ្លួង ស្រុកពញាឮ ខេត្តកណ្ដាល ។

សញ្ញាប័ត្រលេខ ១៧៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ឹម-ទុម នាមធាយា ធម្មជោត អាយុ ៥០ វស្សា ២១ ជាចៅអធិការវត្តធម្មជោត ឃុំមហាខ្ញូង ស្រុកកោះសូទិន ខេត្តកំពង់ចាម ។

សញ្ញាប័ត្រលេខ ១៧៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ លែម-ទ្រា នាមធាយា ឯកគ្គោ កើតឆ្នាំកុរ អាយុ ៥១ វស្សា ១៥ ជាចៅអធិការវត្តចន្ទ្រា ឃុំអំពិលតាពក ស្រុកកោះសូទិន ខេត្តកំពង់ចាម ។

(មានត)